# ឈានវិនិច្ឆ័យ

## សួរ-ឆ្លើយ

ចំពោះទាន

ព្រះគ្រូសិរីសោភ័ណ កិម-តូរ ចន្ទមង្គលោ

វត្តឧណ្ណាលោម

ក្រុមជំនុំព្រះត្រៃបិដក ក្នុងពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

ជាជំនួយសាលាធម្មវិន័យ

ផ្សាយចេញពី

**www.haotrai.com**

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

ANANA
Computer
Trusted Service & Quality

# ទានវិនិច្ឆ័យ

## សួរ-ឆ្លើយ

ចំពោះទាន


ព្រះគ្រូសិរីសោភ័ណ គិម-តូរ ចន្ទមង្គលោ

វត្តឧណ្ណាលោម

ក្រុមជំនុំព្រះត្រៃបិដក ក្នុងពុទ្ធសាសនបណ្ឌិត្យ


រៀបរៀង

ជាជំនួយសាលាធម្មវិន័យ


បោះពុម្ពគ្រាទី ៣

ព.ស. ២៤៩៥



ទុកសិទ្ធិ


---


ការផ្សាររបស់

បណ្ណាគារ ជឹង-ប៉ោ-ហួត

លេខ ១៤០ វិថីព្រះបាទអង្គអេង ភ្នំពេញ


## កថាមគ្គ

បុព្វហេតុដែលនាំឱ្យខ្ញុំរៀបរៀងសៀវភៅនេះឡើង ដោយសេចក្ដីយល់ឃើញថា ពួកពុទ្ធបរិស័ទទូទៅ មានភាគច្រើននិយមក្នុងការធ្វើទានដែលជាកិច្ចងាយហាត់លំបាកជាងធ្វើការកុសលដទៃឯទៀតទាំងអស់ ព្រោះហេតុនោះ បានជាខ្ញុំខំប្រឹងស្រាវជ្រាវរាវរករឿងទានដែលមានក្នុងសូត្រផ្សេងៗ មានវេលាមសូត្រ, ទក្ខិណាវិភង្គសូត្រនិងជាណុស្សោណិសូត្រជាដើម ក្នុងគម្ពីរអង្គុត្តរនិកាយព្រមទាំងអដ្ឋកថា ដកស្រង់មករៀបរៀងជាសៀវភៅនេះឡើងហើយសន្មតឱ្យឈ្មោះថា **ទានវិនិច្ឆ័យ** ប្រែថា ការវិនិច្ឆ័យនូវទាន និងការធ្វើទានរបស់ទាយក-ទាយិកា ។

ក្នុងផ្ទៃសៀវភៅនេះ ខ្ញុំរៀបរៀងតាំងឱ្យមានបញ្ហា សួរ-ឆ្លើយ សូមលោកអ្នកអានពិនិត្យសង្កេតក្នុងបញ្ហានីមួយៗ ឱ្យបានយល់សេចក្ដីច្បាស់លាស់ ទើបយកជាវត្តប្រតិបត្តិបាន ។

សៀវភៅទានវិនិច្ឆ័យនេះ ទុកដូចជាប្រទីបមួយមានរស្មីដ៏រុងរឿងសម្រាប់ឆ្លុះបំភ្លឺឱ្យយល់សេចក្ដីខុសត្រូវក្នុងវិធីធ្វើទានផ្សេងៗ របស់អស់លោកអ្នកសប្បុរសដែលជាទាយក-ទាយិកាទូទៅ ។

សេចក្ដីប្រៀបថា: ធម្មតាកិច្ចការអ្វីនីមួយក្នុងលោក ដូចការធ្វើគ្រឿងឈើមានតុទូជាដើមក្ដី ការធ្វើគ្រឿងដែកមានរថយន្តជាដើមក្ដី ដែលជារបស់អាចឱ្យសម្រេចប្រយោជន៍ តាមបំណងរបស់មនុស្សអ្នកត្រូវការដោយស្រួលទៅបាន លុះតែអាស្រ័យដោយពួកជាងអ្នកធ្វើនោះចេះច្បាប់

គឺខ្នាតរង្វាស់បែបភាព ទាំងប៉ិនប្រសប់ពេលករចនាឱ្យដឹងថាសមឬមិនសមផង ទើបកិច្ចការនោះៗ ដែលកើតឡើងហើយជាទីគាប់ចិត្តនៃអ្នកដទៃទាំងអាចឱ្យសម្រេចផលប្រយោជន៍ដល់ជាងអ្នកធ្វើនោះច្រើនថែមទៀតផង យ៉ាងណាមិញ, ពួកពុទ្ធបរិស័ទជាទាយក-ទាយិកា អ្នកធ្វើទានគួរតែសិក្សាឲ្យជ្រាប់របស់ទានឱ្យបានចេះដឹងសព្វគ្រប់ជាមុន ដើម្បីចៀសវាងកុំឱ្យមានការទាស់ខុសឆ្គងពីពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាតក្នុងវេលាដែលបរិច្ចាគទានម្ដងៗ ទើបទាននោះឯងអាចឱ្យសម្រេចប្រយោជន៍ គឺផលានិសង្សច្រើនដល់អ្នកម្ចាស់ទាននោះឯង ងាយស្រួលដល់បដិគ្គាហកលោកអ្នកទទួលផង ក៏យ៉ាងនោះដែរ ។

ទីបំផុតនៃកថាមគ្គនេះ ខ្ញុំសូមឧទ្ទិសកុសលរាសី ដែលកើតអំពីកម្លាំងព្យាយាមរៀបរៀងសៀវភៅនេះ ជូនចំពោះបុព្វការីទាំងឡាយមានឧបាសិកា **គុណ** និងឧបាសក **កិម** ដែលជាមាតាបិតាបង្កើតរបស់ខ្ញុំជាដើម. ដោយអំណាចកុសលរាសីនេះ សូមឱ្យបុព្វការីទាំងនោះ បានសម្រេចឥដ្ឋមនុញ្ញផលជាទីគាប់ចិត្តកុំបីអាក់ខានឃ្លៀងឃ្លាតឡើង ។

ថ្ងៃទី ៣០ វិច្ឆិកា ២៤៩៥/១៩៥២

ព្រះគ្រូសិរីសោភ័ណ **កិម-ទូរ**

ចន្ទមង្គលោ

វត្តឧណ្ណាលោម ភ្នំពេញ



# នមត្ថុ រតនត្តយស្ស

សូមនមស្សការ ចំពោះព្រះរត្នត្រ័យ ។

**ឬ.** ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់បានត្រាស់ដឹងឡើងក្នុងលោក. ព្រះអង្គបានសំដែងពន្យល់ពុទ្ធបរិស័ទអំពីការឱ្យទាន ដោយន័យច្រើនជាអនេក, បានទាំងទ្រង់ប្រៀនប្រដៅវិធីក្នុងការបរិច្ចាគទានដោយសព្វគ្រប់សឹងមានប្រាកដមកក្នុងគម្ពីរដោយច្រើន តើព្រះអង្គទ្រង់យល់ឃើញគុណគឺការបរិច្ចាគទានយ៉ាងណាខ្លះ ? ទ្រង់យល់ឃើញទោសនិងគុណរបស់ភោគសម្បត្តិយ៉ាងណាខ្លះ ? ទោសនិងគុណរបស់បុគ្គលមិនបរិច្ចាគទាននឹងបរិច្ចាគទានយ៉ាងណាខ្លះ ?

**ឆ.** ព្រះអង្គទ្រង់យល់ឃើញយ៉ាងនេះថា គុណគឺការបំពេញទាននេះជាកល្យាណវត្តមួយដ៏វិសេសដែលធ្លាប់មានជាប់ជាវេណីមកតាំងពីមុនពុទ្ធកាល ហើយចាត់ថាជាមង្គលមួយដ៏ប្រសើររបស់សប្បុរសទាំងឡាយ ។

ចំណែកខាងភោគសម្បត្តិទាំងអស់ក្នុងលោកនេះ រមែងកើតទៅជាទោសក៏មាន ទៅជាគុណក៏មាន ។ ភោគសម្បត្តិណា ដែលនៅក្នុងកណ្ដាប់ដៃរបស់មនុស្សល្ងង់ខ្លៅ ជាអ្នកមិនយល់ប្រយោជន៍ដ៏ធំទូលាយក្នុងកាលឥឡូវនេះនិងកាលខាងមុខ ភោគសម្បត្តិនោះ និងត្រឡប់ទៅជាទោសដល់ខ្លួនជាម្ចាស់វិញដោយពិត ជួនកាលក៏គ្រាន់តែជារបស់កណ្ដាលៗ មិន

សម្រេចប្រយោជន៍ដ៏ធំទូលាយតទៅទៀតក៏មាន ដូចអ្នកមានប្រទីបសម្រាប់អុជបំភ្លឺ តែបើម្ចាស់មិនបានអុជបំភ្លឺទេ ក៏មិនមានប្រយោជន៍អ្វីអំពីប្រទីបនោះឡើយ ។

ភោគសម្ប័ទណា ដែលនៅក្នុងដៃរបស់មនុស្សអ្នកចេះដឹងជាអ្នកយល់ប្រយោជន៍ដ៏ធំទូលាយ ភោគសម្ប័ទនោះ នឹងត្រឡប់ទៅជាគុណដល់ខ្លួនជាម្ចាស់វិញជាប្រាកដ ។ ឯទ្រព្យសម្បត្តិដែលជាគុណឬជាប្រយោជន៍នោះគឺសម្រាប់ចាយវាយចិញ្ចឹមខ្លួន ទំនុកបំរុងមាតាបិតាគ្រូអាចារ្យនិងអន្តោជនពាហិរជន គឺ បុត្តភរិយាទាសកម្មករ, ធ្វើទក្ខិណាទានចំពោះបុព្វជិតក្នុងព្រះពុទ្ធសាសនា ដើម្បីជាបុញ្ញនិធិរបស់ខ្លួន, ធ្វើពលី ៥ យ៉ាងមានញាតិពលីជាដើម ។ ការប្រើប្រាស់ទ្រព្យសម្បត្តិបែបនេះ ឈ្មោះថាពង្រីកឬបណ្ដុះទ្រព្យសម្បត្តិឱ្យបានទៅជាគុណជាប្រយោជន៍ចំរើនធំទូលាយទាំងឥធលោកនិងបរលោក ។

មួយទៀតជនណាជាគ្រហស្ថ មានប្រាជ្ញានៅគ្រប់គ្រងផ្ទះ កាលបើបានលៃលកធនធានឱ្យទានទុកជាកំណប់ ជននោះឈ្មោះថាបានជញ្ជូនទ្រព្យសម្បត្តិទុកដាក់ឱ្យផុតចាកសេចក្ដីអន្តរាយ ដើម្បីជាប្រយោជន៍តទៅសមដូចពុទ្ធភាសិតថា :

**អាទិត្តស្មឹ អគារស្មឹ យំ នីហរតិ ភាជនំ**
**តំ តស្ស ហោតិ អត្ថាយ នោ ច យំ តត្ថ ឌយ្ហតិ**



**ឯវមាទិត្តកោ លោកោ ជរាយ មរណេន ច**
**នីហរេថេវ ទានេន ទិន្នំ ហោតិ សុនីភតំ**

(សេចក្ដីថា) កាលបើផ្ទះត្រូវភ្លើងឆាបឆេះ ជនម្ចាស់ផ្ទះតែងជញ្ជូនទ្រព្យសម្បត្តិមានភាជនៈជាដើមចេញអំពីផ្ទះ ទ្រព្យណាដែលគេប្រញាប់ជញ្ជូនចេញផុត ភ្លើងឆេះមិនបាន ទ្រព្យនោះរមែងបានទៅជាប្រយោជន៍របស់គេតទៅ យ៉ាងណាមិញ; សត្វលោកដែលត្រូវភ្លើង គឺជរានិងមរណៈឆាបឆេះ គួរប្រញាប់ជញ្ជូនចេញឱ្យផុតអំពីផ្ទះគឺរាងកាយដោយការឱ្យទាន ព្រោះថាទានដែលគេឱ្យហើយនោះឯង ឈ្មោះថាបានជញ្ជូនទ្រព្យទុកដោយល្អ មិនឱ្យភ្លើងឆេះបាន ក៏យ៉ាងនោះដែរ ។

សេចក្ដីនេះបំភ្លឺឱ្យឃើញថា កាលបើផ្ទះគឺរាងកាយត្រូវភ្លើងគឺជរានិងមរណៈឆាបឆេះ ទ្រព្យសម្បត្តិដែលនៅក្នុងកំណាន់របស់មច្ឆរិយៈ ដែលគេមិនប្រញាប់ជញ្ជូនយកចេញ ដោយការបំពេញទានទេ ក៏មុខជានឹងត្រូវភ្លើងជរានិងមរណៈឆេះខ្ទេចខ្ទីជាមួយនឹងរាងកាយ ទៅជារបស់ឥតប្រយោជន៍មិនខាន ព្រោះហេតុនោះបានជាព្រះសម្ពុទ្ធទ្រង់សំដែងពន្យល់អំពីគុណសម្បត្តិគឺការឱ្យទានជារឿយៗ ដើម្បីឱ្យកើតប្រយោជន៍ដ៏ធំទូលាយអំពីទ្រព្យសម្បត្តិនោះៗ ដូចសេចក្ដីដែលបានសំដែងមកនេះឯង ។

**ប្ុ.** សត្វទាំងឡាយក្នុងលោក បើពោលតាមប្រភេទនៃពួកសត្វមានប៉ុន្មានពួក ? សត្វទាំងអស់នោះដែលមានជីវិតរស់នៅបានអាស្រ័យ

ដោយអ្វី ? ចូរអធិប្បាយឱ្យហូរហែជាប់ទាក់ទងគ្នាមកមើល !

**វិ.** មានច្រើនពួក ច្រើនឈ្មោះជាអនេក ហួសវិស័យនឹងលើកមកពណ៌នាក្នុងទីនេះឱ្យសព្វគ្រប់បាន. ជីវិតរបស់សត្វដែលនឹងអាចរស់តាំងនៅបាន អាស្រ័យដោយរាងកាយ។ ដែលនឹងប្រព្រឹត្តទៅបាន ក៏ត្រូវអាស្រ័យដោយអាហារ ទើបជីវិតរបស់សត្វនោះ។ អាចរស់នៅបាន. ការរក្សាជីវិតរបស់សត្វទាំងអស់ជាភារៈយ៉ាងធ្ងន់បំផុត, សាច់ឈាមស្បែកសរសៃពណ៌សម្បុរដែលចំរើនស្រស់បស់ឡើងបាន ក៏ព្រោះអាស្រ័យអាហារ កាលបើប្រាសចាកអាហារហើយ សន្តតិរូប គឺរូបដែលចំរើនជាប់តទៅនោះក៏ឈប់ចំរើន រាងកាយទាំងមូលក៏ស្វិតស្រពោនថយចុះទៅជាលំដាប់ ទាំងជីវិតសោតក៏តាំងនៅបានដោយក្រ ។

អាហារជារបស់សំខាន់សម្រាប់ឧបត្ថម្ភជីវិតឱ្យប្រព្រឹត្តទៅ សមដូចព្រះពុទ្ធដីកាថា **សព្វេ សត្តា អាហារដ្ឋិតិកា** ពួកសត្វរាល់រូបមានជីវិតតាំងនៅបានព្រោះអាហារ ។ វត្ថុដទៃក្រៅអំពីអាហារនោះទៀត ជនជាតិជាមនុស្ស ត្រូវមានលំនៅសម្រាប់ជាទីជ្រកកោន, សំពត់សម្រាប់ស្លៀកដណ្តប់, ថ្នាំសម្រាប់កែរោគក្នុងគ្រាដែលត្រូវការ វត្ថុទាំងអម្បាលនេះសុទ្ធតែជារបស់សម្រាប់ឧបត្ថម្ភទប់ទល់ជីវិតដោយពិត ព្រោះហេតុនោះ



មនុស្សសត្វក្នុងលោក បើប្រាសចាករបស់ណាមួយ ជីវិតរមែងតាំងនៅបានដោយលំបាក ឬ តាំងនៅពុំបានសោះឡើយ ។

**បុ.** ជនជាតិមនុស្សទាំងអស់ សុទ្ធតែអាចញ៉ាំងជីវិតនិងរាងកាយឱ្យប្រព្រឹត្តទៅតាមទំនើងខ្លួនឯងបានគ្រប់។ គ្នា ឬត្រូវពឹងពាក់អ្នកដទៃឬក៏ត្រូវអាស្រ័យសម្បត្តិអ្វី ចូរអធិប្បាយមកមើល !

**វិ.** ជនជាតិជាមនុស្សនីមួយ។ លុះតែមានចំណេះវិជ្ជាឬកម្លាំងកាយកម្លាំងប្រាជ្ញាបរិបូណ៌ ទើបអាចស្វែងរកអាហារបានបរិភោគ, រកទីអាស្រ័យនៅ និងគ្រឿងប្រើប្រាស់សំរាប់ជួយជីវិតបានគ្រប់គ្រាន់ល្អ ។ ចំណែកខាងមនុស្សដែលគ្មានចំណេះវិជ្ជានិងខ្សោយកម្លាំង ឬ ឥតគុណសម្បត្តិណាមួយក្នុងខ្លួន ក៏មិនអាចនឹងរក្សាជីវិតរាងកាយឱ្យរស់នៅតាមទំនើងខ្លួនឯងបានឡើយ ។ មនុស្សបែបនេះត្រូវអាស្រ័យពឹងផ្អែកនឹងអ្នកដទៃ ឱ្យគេជួយចិញ្ចឹមជីវិតខ្លួនជាដរាប ព្រោះថាមនុស្សទាំងអស់ក្នុងលោករមែងមានវាសនាឬគុណសម្បត្តិនិងកម្លាំងផ្សេង។ គ្នា ។ ចំណែកខាងមនុស្សដែលខ្សត់ខ្សោយវាសនានិងគុណសម្បត្តិ ឬខ្សោយកម្លាំងកាយនឹងសម្ងំនៅតាមទំនើងខ្លួនឯងមិនបាន ត្រូវធ្វើសមាគមគប់រកមនុស្សដែលសម្បូណ៌វាសនានិងគុណសម្បត្តិឬកម្លាំងកាយ ឱ្យជួយណែនាំបង្ហាត់បង្រៀន ជួយជ្រោមជ្រែងដោយទ្រព្យរបស់ ឬភោជនាហារសំរាប់ចិញ្ចឹមជីវិត ។ មនុស្សដែលមានវាសនានិងគុណសម្បត្តិខ្ពង់ខ្ពស់ ក៏ត្រូវតែទទួលអភិបាលរក្សាមនុស្ស

ដែលខ្សោយវាសនា នៅតូចទន់ខ្ចី ឬថោកទាបជាងខ្លួនដោយកិច្ចប្រៀនប្រដៅនិងទ្រព្យសម្បត្តិជាដើមទុន ឬអាហារសំរាប់បរិភោគរាល់ថ្ងៃជាដរាប ដូចមាតាបិតាជាប្រធាននៃបុត្តធីតា ។ ព្រោះហេតុនោះ ការឱ្យអាហារឬគ្រឿងប្រើប្រាស់គ្រប់យ៉ាងនេះជាកល្យាណប្បវេណី ជាទំនៀមមួយដ៏វិសេស ជាប់មកតាំងអំពីមុនពុទ្ធកាលតាមបាលីលោកហៅថា **ទានៈ** ប្រែថា ការឱ្យ ។

**បុ. ទានៈ** ដល់ប្រែថា ការឱ្យនោះ តើគួរឱ្យដោយអាការយ៉ាងណាខ្លះ? បើឱ្យដូច្នោះ ទាននោះហៅថា ទានអ្វី ?

**វិ.** គួរឱ្យដោយអាការយ៉ាងនេះគឺ បុគ្គលមានចិត្តអាណិតទោរទន់ទៅរកមនុស្សសត្វដទៃ ហើយបានឱ្យគ្រឿងបរិភោគប្រើប្រាស់ដោយសេចក្តីអាណិតតែម្យ៉ាង មិនអាស្រ័យយកបំណាច់ឬកម្លាំងប្រើប្រាស់ការឱ្យទានដូច្នេះហៅថា **ករុណាទាន** ។ បុគ្គលយល់ច្បាស់ក្នុងគុណូបការៈ ឬគុណសម្បត្តិណាមួយរបស់លោកអ្នកមានគុណមានមាតាបិតាគ្រូអាចារ្យ ឬលោកអ្នកទ្រទ្រង់នូវគុណមានសីលគុណជាដើម ក៏ធ្វើទានចំពោះអ្នកមានគុណនោះ ការឱ្យទានដូច្នេះហៅថា **បូជាទាន** ឬនឹងហៅថា **បដិការៈទាន** វិញក៏បាន ។ បុគ្គលមានចិត្តធូរទូលាយចង់ឱ្យប្រយោជន៍ឱ្យសេចក្តីសុខសេចក្តីចំរើន ដល់អ្នកដទៃដែលជាញាតិសាលោហិត ឬមិត្រសម្លាញ់ ឬ ក៏



ជាមនុស្សរួមជាតិជាមួយគ្នា ដែលល្មមទទួលអំណោយការសង្គ្រោះបាន ហើយចែកទ្រព្យសម្បត្តិជាដើមទុនក្តី គ្រឿងបរិភោគគ្រឿងប្រើប្រាស់ក្តី ដើម្បីទំនុកបំរុងជួយកម្លាំងសង្គ្រោះឱ្យកើតប្រយោជន៍ស្មើមុខគ្នាឡើង, ការឱ្យទានដូច្នេះហៅថា **អនុគ្គហទាន** ឬនឹងហៅថា **សង្គហទាន** វិញក៏បាន ។

**បុ. ទានៈ** និង **ចាគៈ** ព្រះសម្ពុទ្ធទ្រង់សំដែងទុកដោយន័យច្រើនកន្លែង សឹងមានប្រាកដមកក្នុងស្ថានធម៌ផ្សេងៗ គឺក្នុងអនុបុព្វកថាខ្លះ ក្នុងសប្បុរិសប្បញ្ញត្តិខ្លះ ក្នុងបុញ្ញកិរិយាវត្ថុខ្លះ ក្នុងទសពិធរាជធម៌ខ្លះ ក្នុងអរិយទ្រព្យខ្លះ ក្នុងអធិដ្ឋានធម៌ខ្លះ ក្នុងសង្គហធម៌ខ្លះ ក្នុងសម្បរាយិកត្ថធម៌ខ្លះ ក្នុងឧបនិស្ស័យធម៌ខ្លះ តើមានសេចក្តីអធិប្បាយដូចគ្នាឬផ្សេងគ្នាយ៉ាងណាខ្លះ ?

**វិ.** បើពោលសំដៅយកសេចក្តី ឃើញប្រាកដថាផ្សេងគ្នា បើពោលតាមលក្ខណៈក៏ឃើញថាស្រដៀងៗ គ្នា ចំណែកខាងទានៈមានន័យ ៤ យ៉ាងដូចសេចក្តីដែលត្រូវអធិប្បាយតទៅនេះគឺ :

**១.** **ទានៈ** ការឱ្យវត្ថុណាមួយដែលនៅជាប់ជំពាក់ដោយមច្ឆរិយៈ ឬ ឱ្យដោយស្ទាក់ស្ទើរមិនជ្រះស្រឡះចាកមច្ឆរិយៈ ឬឱ្យតាមទំលាប់ទំនៀមត្រកូលរបស់គេ មិនមែនជាកិច្ចអស្ចារ្យចំឡែកជាងត្រកូលដែលធ្លាប់ធ្វើមកប៉ុន្មាន ។

**២. ទាន:** ការឱ្យដែលជាប់ដោយតណ្ហា គឺបុគ្គលអ្នកឱ្យទានមានប្រាថ្នាយកសិរីសួស្តីនិងផលប្រយោជន៍មកខ្លួនវិញ ចំពោះសាមិសសុខក្នុងក្នុងភពនេះ ឬ ភពខាងមុខ ។

**៣. ទាន:** ការឱ្យមិនសមគួរ បុគ្គលណាមានទ្រព្យសម្បត្តិច្រើនមានវត្ថុដ៏ថ្លៃថ្លាច្រើន លុះត្រូវការចាត់ចែងទាន ក៏ចាត់ចែងធ្វើដោយរលីបរលាបស្ដួចស្ដើង នឹង វត្ថុដ៏ថោកទាបតាមធម្មតា ទានរបស់បុគ្គលនោះឈ្មោះថា ជាទានមិនសមតាមសក្តិតាមកម្លាំងនៃទ្រព្យសម្បត្តិដែលខ្លួនមាន ។

**៤. ទាន:** ការឱ្យចំពោះមុខបដិគ្គាហក: អ្នកទទួលផ្ទាល់ដែលជាបុគ្គលខ្សត់ខ្សោយដោយគុណធម៌និងទ្រព្យសម្បត្តិ ឬ ខ្ពង់ខ្ពស់ដោយគុណធម៌ ទាំងនេះជាសេចក្តីអធិប្បាយរបស់ពាក្យថាទាន: ។

ចំណែកខាងចាគ:ក៏មានសេចក្តីអធិប្បាយចែកចេញជា ៤ យ៉ាងដែរគឺ

**១. ចាគ:** ការលះវត្ថុណាមួយ ចំពោះបដិគ្គាហក: ដើម្បីលះបង់ឬសង្កត់សង្កិននូវលោភ:និងមច្ឆរិយ:ឱ្យស្រាលស្តើងចាកសន្តាន គឺចំណាយទ្រព្យធនដើម្បីទុកជាអលង្ការ ឬជាកល្យាណវត្តរបស់ចិត្ត មិនបណ្តោយឱ្យចិត្តឈ្លក់ជាប់នៅក្នុងកិលេស ។



**២. ចាគ:** ការលះឱ្យ ដែលមិនជាប់ជំពាក់ដោយតណ្ហា គឺឱ្យដោយបំណងចំពោះនិរាមិសសុខ ដើម្បីធ្វើចិត្តឱ្យបរិសុទ្ធ បើកឱកាសឱ្យបញ្ញារបស់ខ្លួនមានកម្លាំងលូតលាស់ចំរើនឡើងផង ដើម្បីប្រយោជន៍និងសេចក្តីសុខថ្មីថ្មើងជាតម្រាប់ដល់យុវជនជាន់ក្រោយផង តួយ៉ាងដូចការចំណាយទ្រព្យសម្បត្តិ ទំនុកបំរុងក្នុងព្រះពុទ្ធសាសនាកសាងសេនាសន:លើកថ្នល់សង់ស្ពាន ជីកអណ្តូងទឹក សង់សាលាបំរុងការសិក្សា ឬសាលាសំណាក់ទុកសម្រាប់ជាសាធារណ: មិនបានចំពោះបដិគ្គាហក: ។

**៣. ចាគ:** ការលះឱ្យវត្ថុដ៏ច្រើនក្រៃលែង ឬខ្ពង់ខ្ពស់លើសវិស័យរបស់មនុស្សសាមញ្ញក្នុងលោក គួរឱ្យស្ញើច ដែលរាប់ថាជាការបរិច្ចាគយ៉ាងខ្ពង់ខ្ពស់បំផុត កម្រអ្នកផងយកតម្រាប់តាមបាន តួយ៉ាងដូចមហាបរិច្ចាគរបស់ព្រះពោធិសត្វ ។

**៤. ចាគ:** ការលះកាត់អាល័យក្នុងជីវិតនិងសេចក្តីសុខ ក្នុងទ្រព្យសម្បត្តិរបស់ខ្លួនម្នាក់ឯង ដើម្បីស្វែងរកឧបាយជួយជ្រោមជ្រែងប្រជាជនក្នុងលោក ឬលះបង់ទ្រព្យសម្បត្តិដើម្បីរាយរាយចែកចាយឱ្យទៅជាប្រយោជន៍ ផ្តល់សេចក្តីសុខសេចក្តីចំរើនរុងរឿងដល់មហាជនទុកជាកេរ្តិ៍ដំណែលតទៅ ។ ពាក្យថា **ទាន:** និង **ចាគ:** មានសេចក្តីអធិប្បាយផ្សេងគ្នាដូចពណ៌នាមកនេះឯង ។

**ម្ម. ទាន** និង **ចាគ:** ទាំងពីរនេះ ណាមានកម្លាំងជាងណា ?

ណាជាហេតុ ណាជាផល ?

**ទិ.** **ចាគៈ** មានកម្លាំងមានអានុភាពខ្ពង់ខ្ពស់ផ្សាយរស្មីរុងរឿងលេចសេចក្តីទូលាយល្អជាងទានៈ ។ មួយទៀត **ទានៈ** និង **ចាគៈ** នេះបើពោលតាមលក្ខណៈរូបរួមក៏គឺការឱ្យ ការចែករំលែកទ្រព្យសម្បត្តិចំពោះសត្វបុគ្គលដទៃប៉ុណ្ណោះឯង តែបើពោលតាមហេតុផលវិញ **ទានៈ** ជាឈ្មោះបរិក្ខារវត្ថុដែលត្រូវឱ្យ, **ចាគៈ** ជាឈ្មោះចេតនាដែលជាតួចេតសិកសម្រាប់លះ, **ទានៈ** ចាត់ជាផល, **ចាគៈ** ចាត់ជាហេតុ អាស្រ័យគ្នាដូចដួងព្រះអាទិត្យនិងពន្លឺរស្មីនៃព្រះអាទិត្យ ។ មួយវិញទៀត **ទាន** ដូចជាផ្លែផ្កាដែលលេចចេញចាកដើមឫទង, **ចាគៈ** ដូចជាដើមឫទងនៃរុក្ខជាតិនិងវល្លិជាតិ ជាបច្ច័យឱ្យកើតផ្លែផ្កា ឬ ថា **ចាគៈ** ទុកដូចជាដើមពូជមុនដំបូង, **ទានៈ** ទុកដូចជាផ្លែផ្កាដែលកើតអំពីពូជខាងដើមដូច្នេះវិញក៏បាន ។

**ឫ.** ការឱ្យទានមានកម្រៃ នាំឱ្យសម្រេចប្រយោជន៍ដូចម្តេចខ្លះ ?

**ទិ.** មានកម្រៃនាំឱ្យសម្រេចប្រយោជន៍គឺសេចក្តីល្អ សេចក្តីសុខនិងសេចក្តីចំរើនទាំងក្នុងបច្ចុប្បន្ននិងបរលោក ដល់បុគ្គលអ្នកធ្វើនោះជាច្រើនប្រការ ។

**ឫ.** **ទាន** មានច្រើនអនេក មិនអាចនឹងពណ៌នាឱ្យសព្វគ្រប់បាន តែបើកំណត់ឈ្មោះទានតាមប្រភេទដែលផ្សេងគ្នា ដោយចេតនានិងទេយ្យវត្ថុ



មានប៉ុន្មានយ៉ាង ?

**ទិ.** មាន ៣ យ៉ាងគឺៈ

**១. ចាគចេតនា ទានំ** ចេតនាដែលលះទេយ្យវត្ថុឱ្យដល់បុគ្គលដទៃ ឈ្មោះថា ទាន ។

**២. វិរតិ ទានំ** ចេតនាដែលវៀរចាកអំពើអាក្រក់ មានវៀរចាកបាណាតិបាតជាដើម ឈ្មោះថា ទាន ។

**៣. ទេយ្យធម្មោ ទានំ** ទេយ្យធម៌គឺវត្ថុដែលគេត្រូវលះឱ្យដល់បុគ្គលដទៃ ឈ្មោះថា ទាន ។

**ឫ.** មាតិកាដែលរាប់ឈ្មោះទាន ៣ យ៉ាងមកនោះ គ្រាន់តែប្រែតាមរូបព្យញ្ជនៈខ្លីៗ ស្តាប់សេចក្តីមិនទាន់បាន តើមានសេចក្តីផ្សេងគ្នាឬជាប់ទាក់ទងគ្នាយ៉ាងណា ? ចូរអធិប្បាយ !

**ទិ.** ផ្សេងគ្នាខ្លះ ជាប់ទាក់ទងគ្នាខ្លះ បណ្តាទានទាំង ៣ យ៉ាងនេះលើកវិរតិទានចេញមិនអធិប្បាយក្នុងទីនេះ ព្រោះលោកចាត់ជាអភយទានបានដល់ការកាន់សីល ៥ ឯណោះដោយឡែក, ឯចាកចេតនាទាន និងទេយ្យធម្មទានទាំងពីរនេះ ពិតជាមានឈ្មោះផ្សេងគ្នាតាមប្រភេទមែនប៉ុន្តែជាធម្មជាតដាច់ឃ្លាតចេញពីគ្នាមិនបាន ទាំងមិនអាចនឹងញុំាងកុសលឱ្យសម្រេចបានដោយឡែកពីគ្នាឡើយ ព្រោះថា បើបុគ្គលមានតែចេតនាបំរុងលះឱ្យ តែគ្មានទេយ្យវត្ថុនឹងលះឱ្យ ក៏ធ្វើជាទានមិនកើត **ឬ** មាន

ទេយ្យវត្ថុល្អមនឹងលះឱ្យដែរ តែគ្មានចេតនាសម្រាប់លះឱ្យ ក៏ធ្វើឱ្យកើតជាទានមិនបាន លុះតែមានចេតនានិងទេយ្យវត្ថុព្រមគ្នាទាំងពីរ ទើបបុគ្គលធ្វើឱ្យសម្រេចកើតទៅជាទានឡើងបាន ។

**បុ.** **ទាន** បើចែកតាមគោលដើមមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

**វិ.** មាន ២ យ៉ាងគឺ **អាមិសទាន ១ ធម្មទាន ១ ៗ**

**បុ.** ទានទាំងពីរយ៉ាងនោះ លើកធម្មទានទុកសិន សូមសួរចំពោះតែអាមិសទាន ៗ បានដល់ការលះឱ្យវត្ថុអ្វីខ្លះ ?

**វិ.** បានដល់ការលះឱ្យទេយ្យវត្ថុគឺបច្ច័យ ៤ យ៉ាង និងទានវត្ថុ ១០ យ៉ាង ។

**បុ.** ពាក្យថា **បច្ច័យ** ប្រែថាដូចម្ដេច ? បានសេចក្ដីយ៉ាងណា ? ដែលថាមាន ៤ យ៉ាងនោះគឺអ្វីខ្លះ ?

**វិ.** ប្រែថា វត្ថុជាគ្រឿងអាស្រ័យប្រព្រឹត្តទៅរបស់សត្វ, បានសេចក្ដីថា គ្រឿងដែលសត្វត្រូវអាស្រ័យបរិភោគប្រើប្រាស់ហើយប្រព្រឹត្តនៅបាន ឬថាសត្វទាំងឡាយក្នុងលោក សុទ្ធតែត្រូវពឹងពាក់អាស្រ័យនូវបច្ច័យ បើយ៉ាងហោចទៅត្រឹមតែបច្ច័យណាមួយ ទើបអាចញ៉ាំងជីវិតឱ្យប្រព្រឹត្តទៅបាន បើមិនបានអាស្រ័យសោះទេ ក៏នឹងមិនអាចញ៉ាំងជីវិតឱ្យប្រព្រឹត្តទៅបានឡើយ ព្រោះហេតុនោះ ទើបបានឈ្មោះថា **បច្ច័យៈ** ដែលថាមាន ៤ **យ៉ាងនោះគឺ**



**១. ចីវរ** គឺសំពត់សម្រាប់ស្លៀកដណ្ដប់របស់បព្វជិត មានអន្តរវាសកៈ (ស្បង់) ជាដើម ហៅថា ចីវរបច្ច័យ ។

**២. បិណ្ឌបាត** គឺអាហារសម្រាប់បរិភោគ (ឆាន់) របស់បព្វជិត មានខាទនីយៈ និងភោជនីយៈជាដើម ដែលគួរទទួលទុកឆាន់បាន តាំងពីវេលាអរុណរះទៅទល់ថ្ងៃត្រង់ហៅថា បិណ្ឌបាតបច្ច័យ ។

**៣. សេនាសនៈ** គឺវត្ថុជាទីដេកនិងវត្ថុជាទីអង្គុយរបស់បព្វជិត មានកុដិ, សាលា, គ្រែ, និងតាំងជាដើម ហៅថា សេនាសនបច្ច័យ ។

**៤. គិលានភេសជ្ជៈ** គឺថ្នាំសម្រាប់ព្យាបាលកែបំបាត់ជម្ងឺផ្សេងៗរបស់បព្វជិត មានទឹកបាន ៨ យ៉ាងនិងថ្នាំត្រាំដោយទឹកមូត្រជាដើម ដែលគួរទទួលទុកឆាន់បានតាមកំណត់កាល ហៅថា គិលានភេសជ្ជបច្ច័យ ។

**បុ.** **ទានវត្ថុ** ប្រែថាដូចម្ដេច ? ដែលថាមាន ១០ យ៉ាងនោះគឺអ្វីខ្លះ ?

**វិ.** ប្រែថាវត្ថុសម្រាប់ឱ្យឬរបស់ដែលគេគប្បីឱ្យ, មាន១០យ៉ាងគឺ **១. អន្នំ** បាយ, **២. បានំ** ទឹក, **៣. វត្ថំ** សំពត់, **៤. យានំ** យាន, **៥. មាលា** កម្រងផ្កា, **៦. គន្ធំ** គ្រឿងក្រអូប, **៧. វិលេបនំ** គ្រឿងលាប, **៨. សេយ្យំ** ទីដេក, **៩. អាវសថំ** លំនៅ, **១០. បទីបេយ្យំ** គ្រឿងប្រទីប ។

**បុ.** ទានវត្ថុទាំង ១០ យ៉ាងដែលរាប់មាតិកា ប្រែជាសេចក្ដីខ្លីៗ មក

ប៉ុណ្ណោះស្ដាប់មិនទាន់បាន ចូរអធិប្បាយក្នុងមាតិកាមួយៗ ឱ្យល្មមដល់ការស្ដាប់បានមកមើល ?

**វិ.** ត្រង់ពាក្យថា **បាយ** សំដៅយកគ្រឿងស៊ីគឺខាទនីយៈនិងភោជនីយៈ (បង្អែមនិងចំអាប) ទាំងអស់ជាដើម ។ ពាក្យថា **ទឹក** សំដៅយកទឹកបាន៨យ៉ាង មានទឹកបានដែលគេធ្វើដោយផ្លែស្វាយជាដើម ។ ពាក្យថា **សំពត់** សំដៅយកសំពត់សម្រាប់ស្លៀកនិងសំពត់សម្រាប់ដណ្ដប់ជាដើម ។ ពាក្យថា **យាន** សំដៅយកវត្ថុដែលជាគ្រឿងញុំាងដំណើរឱ្យសម្រេច មានរថនិងវហ័ជាដើម មានស្បែកជើងជាទីបំផុត ។ ពាក្យថា **កម្រងផ្កា** សំដៅយកផ្កាឈើទាំងអស់ ដែលគ្រាន់តែផ្សេងគ្នាដោយពណ៌និងក្លិន ។ ពាក្យថា **គ្រឿងក្រអូប** សំដៅយកគន្ធជាតទាំងអស់និងគ្រឿងឧបករណ៍ដល់គ្រឿងក្រអូប ដែលគេកិនហើយក្ដី មិនទាន់បានកិនក្ដី ។ ពាក្យថា **គ្រឿងលាប** សំដៅយកវត្ថុសម្រាប់ធ្វើស្បែកខាងក្រៅឱ្យជាទីត្រេកអរ ។ ពាក្យថា **ទីដេក** សំដៅយកវត្ថុដែលគួរជាទីដេក-អង្គុយបាន មានគ្រែ, តាំង, ចៀមនិងព្រំជាដើម ។ ពាក្យថា **លំនៅ** សំដៅយកផ្ទះ រោងជាទីសំណាក់អាស្រ័យសម្រាប់បន្ទោបង់នូវសេចក្ដីអន្តរាយ សេចក្ដីលំបាក មានខ្យល់និងកំដៅថ្ងៃជាដើម ។ ពាក្យថា **គ្រឿងប្រទីប** សំដៅយកវត្ថុសម្រាប់ទំនុកបំរុងដល់ប្រទីប មានប្រេងនិងអំបែងប្រទីបជាដើម ។



**បុ.** ទឹកបាន ៨ យ៉ាងនោះ សំដៅយកទឹកដែលគេធ្វើដោយវត្ថុអ្វីខ្លះ?

**វិ.** ទឹកដែលគេធ្វើដោយផ្លែឈើ ៨ យ៉ាងគឺ **១~ អម្ពបានំ** ទឹកបានដែលគេធ្វើដោយផ្លែស្វាយ, **២~ ជម្ពុបានំ** ទឹកបានដែលគេធ្វើដោយផ្លែព្រីង, **៣~ ចោចបានំ** ទឹកបានដែលគេធ្វើដោយផ្លែចេកមានគ្រាប់, **៤~ មោចបានំ** ទឹកបានដែលគេធ្វើដោយផ្លែចេកឥតគ្រាប់, **៥~ មធុកបានំ** ទឹកបានដែលគេធ្វើដោយផ្លែស្រគំ, **៦~ មុទ្ទិកបានំ** ទឹកបានដែលគេធ្វើដោយផ្លែចន្ទ, **៧~ សាលុកបានំ** ទឹកបានដែលគេធ្វើដោយមើមនៃជលជាត មានព្រលិតក្រហមជាដើម, **៨~ ផារុសកបានំ** ទឹកបានដែលគេធ្វើដោយផ្លែមាក់ប្រាង ។

**បុ.** ទឹកបានមានត្រឹមតែ ៨ យ៉ាងប៉ុណ្ណោះទេ ឬមានផ្សេងពីនេះទៀតដែរ បើមានតើអ្វីខ្លះ ?

**វិ.** មានផ្សេងពីនេះទៀត ៨ យ៉ាគឺ **១~ កោសម្ពបានំ** ទឹកបានដែលគេធ្វើដោយផ្លែសង្ស៊ារ, **២~ កោលបានំ** ទឹកបានដែលគេធ្វើដោយផ្លែពុទ្រាតូច, **៣~ ពទរបានំ** ទឹកបានដែលគេធ្វើដោយផ្លែពុទ្រាធំ, **៤~ ឃតបានំ** ទឹកបានដែលគេធ្វើដោយទឹកដោះរាវ ឬ ទឹកដោះថ្លា, **៥~តេលបានំ** ទឹកបានដែលគេធ្វើដោយប្រេងល្ង មានប្រេងល្ងជាដើម, **៦~បយោបានំ** ទឹកបានដែលគេធ្វើដោយទឹកដោះស្រស់, **៧~ យាគុបានំ**

ទឹកបានដែលគេធ្វើដោយបបរ, **៨- រសបានំ** ទឹកបានដែលគេធ្វើដោយរសជាតិនៃវត្ថុមាន បន្លែជាដើម ។

**ឫ.** ទឹក **បាន** នោះ ធ្វើបានគ្រប់ផ្លែឈើនិងវត្ថុឯទៀតទាំងអស់ឬ ? មានពុទ្ធប្បញ្ញត្តិឱ្យវៀរវត្ថុណាខ្លះ ? ចូររាប់ចំនួននិងឈ្មោះមកផង !

**វិ.** មិនមែនចេះតែធ្វើបានគ្រប់ផ្លែឈើនិងវត្ថុឯទៀតទាំងអស់ទេ,មានពុទ្ធប្បញ្ញត្តិឱ្យវៀរមហាផល (ផ្លែឈើធំ) ៩ យ៉ាងចេញគឺ ត្នោត, ដូង, ខ្នុរ, ខ្នុរសម្លរ, ឃ្លោក, ល្ពៅ, ត្រសក់, ឪឡឹក, ត្រឡាច; និងធញ្ញជាតិ (ជាតិនៃស្រូវ) ៧ យ៉ាងចេញគឺ ស្រូវស, ស្រូវដំណើប, ស្រូវក្រហម, ស្រងែ, ស្កោ, ស្គួយ ឬកន្ទុយដំរី និងគែលលក ។ ផ្លែឈើក្រៅពីមហាផល ៩ យ៉ាង និងធញ្ញជាតិ ៧ យ៉ាង នេះចេញ មានពុទ្ធានុញ្ញាតឱ្យធ្វើបានទាំងអស់ ។

**ឫ.** ទឹកបាន ជាភេសជ្ជៈសម្រាប់ភិក្ខុមានជម្ងឺ, បណ្ដាកាលិកទាំង ៤ ទឹកបានចាត់ចូលក្នុងកាលិកណា ? ភិក្ខុឆាន់បានក្នុងកាលណា ? ទទួលទុកបានប៉ុន្មានថ្ងៃ ? បើទុកឱ្យហួសកំណត់ហើយយកមកឆាន់ត្រូវអាបត្តិអ្វី ?

**វិ.** ចាត់ចូលក្នុងយាមកាលិក, ភិក្ខុឆាន់ក្នុងវិកាលបាន, ទទួលទុកបានត្រឹម ១ ថ្ងៃ ១ យប់យ៉ាងយូរ, បើទុកឱ្យកន្លងហួសពីកំណត់នោះទៅហើយយកមកឆាន់ ត្រូវអាបត្តិទុក្កដ ។

**ឫ. អាមិសទាន** ព្រះសម្មាសម្ពុទ្ធជាធម្មស្សាមី (ជាម្ចាស់នៃធម៌)[១]

១ ជាម្ចាស់ព្រោះធម៌ ក៏បាន ។



ទ្រង់ត្រាស់សំដែងញែកឈ្មោះតាមលក្ខណៈ ឬ កិច្ចដែលធ្វើនោះ មានប៉ុន្មានប្រការ ? អ្វីខ្លះ ?

**វិ.** មានច្រើនប្រការគឺ **បាដិបុគ្គលិកទាន សង្ឃគតាទាន សប្បុរិសទាន, អសម្មតទាន, កាលទាន ជាដើម**

**ឫ.** ទានដែលទាយកឱ្យចំពោះបុគ្គលមួយៗ តាមសេចក្ដីស្រឡាញ់ ឬសេចក្ដីពេញចិត្ត គឺឱ្យដោយតាំងចិត្តថាលោកនេះជាគ្រូអាចារ្យ, នេះជាញាតិមិត្រ, នេះជាកូនចៅជាដើម ហៅថាទានអ្វី ? មានប៉ុន្មានយ៉ាង ?

**វិ.** ហៅថា **បាដិបុគ្គលិកទាន**, មាន ១៤ យ៉ាង គឺ

១- បុគ្គលឱ្យទាន ដល់ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ

២- បុគ្គលឱ្យទាន ដល់ព្រះបច្ចេកពុទ្ធ

៣- បុគ្គលឱ្យទាន ដល់ព្រះអរហន្តជាសាវ័ករបស់ព្រះតថាគត

៤- បុគ្គលឱ្យទាន ដល់បុគ្គលដែលប្រតិបត្តិ ដើម្បីឱ្យបានលុះនូវអរហត្តផល

៥- បុគ្គលឱ្យទាន ដល់អនាគាមិបុគ្គល

៦- បុគ្គលឱ្យទាន ដល់បុគ្គលដែលប្រតិបត្តិ ដើម្បីឱ្យបានលុះនូវអនាគាមិផល

៧- បុគ្គលឱ្យទាន ដល់សកទាគាមិបុគ្គល

៨- បុគ្គលឱ្យទាន ដល់បុគ្គលដែលប្រតិបត្តិ ដើម្បីឱ្យបានលុះនូវសកទាគាមិផល

៩- បុគ្គលឱ្យទាន ដល់សោតាបន្នបុគ្គល

១០- បុគ្គលឱ្យទាន ដល់បុគ្គលដែលប្រតិបត្តិ ដើម្បីឱ្យបានលុះនូវសោតាបត្តិផល

១១- បុគ្គលឱ្យទាន ដល់បុគ្គលខាងក្រៅព្រះពុទ្ធសាសនា តែមានសេចក្ដីនឿយណាយក្នុងកាម

១២- បុគ្គលឱ្យទាន ដល់បុគ្គលជាបុថុជ្ជនមានសីលបរិសុទ្ធ

១៣- បុគ្គលឱ្យទាន ដល់បុគ្គលជាបុថុជ្ជន ទ្រុស្តសីល

១៤- បុគ្គលឱ្យទាន ដល់សត្វតិរច្ឆាន ។

**ម្ុ.** ឱ្យទានចំពោះរូបបដិគ្គាហកៈមួយៗ តាំងពីព្រះពុទ្ធជាម្ចាស់ចុះមកដល់សត្វតិរច្ឆានជាទីបំផុត ហៅថា បាដិបុគ្គលិកទានៗ នេះមានអានិសង្សស្មើៗគ្នា ឬតិចច្រើនជាងគ្នាយ៉ាងណាខ្លះ? ចូរអធិប្បាយមកមើល !

**ទិ.** មានអានិសង្សមិនស្មើគ្នាទេ គឺមានចំនួនតិចច្រើនជាងគ្នាតាមគុណធម៌របស់បដិគ្គាហកៈនោះៗ ដូច្នេះគឺ ឱ្យទានដល់សត្វតិរច្ឆានបានអានិសង្ស[(១)] មួយរយអត្តភាព ឬ មួយរយជាតិ ។

ឱ្យទានដល់បុគ្គលជាបុថុជ្ជនទ្រុស្តសីល បានអានិសង្សមួយពាន់អត្តភាព ។

ឱ្យទានដល់បុគ្គលជាបុថុជ្ជនមានសីលបរិសុទ្ធ បានអានិសង្សមួយសែនអត្តភាព ។

១- អាយុ. ពណ្ណសម្បុរកាយ. សុខ. កម្លាំង. ប្រាជ្ញា. ទាំង ៥ នេះហៅថាអានិសង្ស ។



ឱ្យទានដល់បុគ្គលខាងក្រៅព្រះពុទ្ធសាសនា ដែលមានសេចក្ដីនឿយណាយក្នុងកាម បានអានិសង្សមួយសែនកោដិអត្តភាព ។

ឱ្យទានដល់បុគ្គលដែលប្រតិបត្តិ ដើម្បីឱ្យបានលុះនូវសោតាបត្តិផល បានអានិសង្សរាប់ពុំបានប្រមាណពុំអស់ឡើយ ។

ចំណែកខាងអានិសង្សនៃទាន ដែលបុគ្គលបានឱ្យដល់សោតាបន្នបុគ្គលក្ដី បុគ្គលដែលប្រតិបត្តិដើម្បីឱ្យបានលុះនូវសកទាគាមិផលក្ដី ព្រះសកទាគាមិបុគ្គលក្ដី បុគ្គលដែលប្រតិបត្តិដើម្បីឱ្យបានលុះនូវអនាគាមិផលក្ដី ព្រះអនាគាមិបុគ្គលក្ដី បុគ្គលដែលប្រតិបត្តិដើម្បីឱ្យបានលុះនូវអរហត្តផលក្ដី ព្រះអរហន្តជាសាវ័ករបស់ព្រះតថាគតក្ដី ព្រះបច្ចេកពុទ្ធក្ដី ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធក្ដី មិនបាច់និយាយឡើយ ។

**ម្ុ.** ទានដែលទាយកឱ្យចំពោះសង្ឃ មិនបានចំពោះរូបបុគ្គលមួយៗ ហៅថាទានអ្វី ? មានចំនួនប៉ុន្មានយ៉ាង ?

**ទិ.** ហៅថា **សង្ឃគតទាន** ឬ **សង្ឃគតទក្ខិណាទាន**, មាន ៧ យ៉ាងគឺ:

១- បុគ្គលឱ្យទាន ចំពោះឧភតោសង្ឃ[(១)] គឺទាំងភិក្ខុសង្ឃនិងភិក្ខុនិ

១-ឧភតោសង្ឃ ប្រែថា សង្ឃទាំងពីរចំណែក គឺពួកភិក្ខុសង្ឃអង្គុយម្ខាង ពួកភិក្ខុនីសង្ឃអង្គុយម្ខាង ព្រះសាស្ដាជាម្ចាស់គង់ត្រង់កណ្ដាលដូច្នេះឈ្មោះថា សង្ឃទាំងពីរចំណែកមានព្រះពុទ្ធជាប្រធាន ។ សង្ឃគតទក្ខិណាទានទី ១ នេះ គ្មានទក្ខិណាទានឯណាវិសេស ត..

សង្ឃមានព្រះពុទ្ធជាប្រធាន

២- បុគ្គលឱ្យទាន ចំពោះឧភតោសង្ឃ ក្នុងកាលដែលព្រះតថាគតបរិនិព្វានកន្លងទៅហើយ

៣- បុគ្គលឱ្យទាន ចំពោះតែភិក្ខុសង្ឃ

៤- បុគ្គលឱ្យទាន ចំពោះតែភិក្ខុនីសង្ឃ

៥- បុគ្គលឱ្យទាន ចំពោះភិក្ខុសង្ឃដែលគេនិមន្តយកអំពីសំណាក់ឧភតោសង្ឃ

៦- បុគ្គលឱ្យទាន ចំពោះភិក្ខុដែលគេនិមន្តយកអំពីសំណាក់ភិក្ខុសង្ឃ

៧- បុគ្គលឱ្យទាន ចំពោះភិក្ខុនីដែលគេនិមន្តយកអំពីសំណាក់ភិក្ខុនីសង្ឃ ។

---

ស្មើឡើយ ប៉ុន្តែកាលដែលព្រះសាស្តាបរិនិព្វានទៅហើយនោះ គេតំកល់ព្រះបដិមាករ ឬព្រះធាតុ លើអាសនៈក្នុងទីចំពោះមុខសង្ឃទាំងពីរចំណែក តំកល់ម្ហូបចំណើលើតុឬជើងស្រាប ហើយធ្វើកិច្ចទក្ខិណោទកជាដើម ថ្វាយវត្ថុទាំងពួងដល់ព្រះបដិមាករជាមុន ទើបថ្វាយដល់សង្ឃទាំងពីរចំណែកខាងក្រោយ យ៉ាងនេះក៏ឈ្មោះថាថ្វាយទានដល់សង្ឃទាំងពីរចំណែកមានព្រះពុទ្ធជាប្រធានដែរ ( សម័យឥឡូវនេះគ្មានភិក្ខុនី មានតែភិក្ខុដូច្នេះឈ្មោះថា ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន) ។ ភោជនដែលថ្វាយដល់ព្រះបដិមាករយ៉ាងនេះ ត្រូវប្រគេនដល់ភិក្ខុណាដែលប្រតិបត្តិព្រះបដិមាករ ដែលបរិបូណ៌ដោយវត្តប្រតិបត្តិ ព្រោះជាវត្ថុរបស់ព្រះពុទ្ធជាបិតា ត្រូវបានដល់ភិក្ខុជាកូន ឬនិងប្រគេនដល់សងក៏គួរ ។ បើវត្ថុនោះជាប្រេងឬសាដក ត្រូវអុជប្រទីបរងជាទង់ឬពិតានថ្វាយ ។ អដ្ឋកថាសុត្តន្តបិដក ។



**បុ.** ទានទាំងពីរគឺបាដិបុគ្គលិកទាននិងសង្ឃគតាទាន ណាមានផលានិសង្សច្រើនជាងណា ? ព្រោះហេតុអ្វី ?

**វិ.** សង្ឃគតាទាន មានផលានិសង្សច្រើនជាងបាដិបុគ្គលិកទាន ព្រោះឱ្យជាសាធារណៈមិនចំពោះរូបបដិគ្គាហកៈម្នាក់ៗ ។

**បុ.** ទានបែបណាហៅថា **សប្បុរិសទាន** ? មានប៉ុន្មានយ៉ាង ? អ្វីខ្លះ? ចូរប្រែហើយអធិប្បាយសេចក្តីឱ្យល្មមស្តាប់បានផង ?

**វិ.** ទានរបស់បុគ្គលជាសប្បុរសហៅថា **សប្បុរិសទាន**, មាន ៥ យ៉ាងគឺ :

**១~ សទ្ធាយ ទានំ ទេតិ** ឱ្យទានដោយសទ្ធា គឺឱ្យដោយចិត្តជឿកម្មនិងផលរបស់កម្មជាក់ប្រាកដថា អំពើគឺការឱ្យទាននេះ ជាអំពើមិនសូន្យសោះអសារឥតការឡើយ ប្រាកដជានឹងត្រឡប់បានផលជារង្វាន់មកវិញពុំខាន

**២~ សក្កច្ចំ ទានំ ទេតិ** ឱ្យទានដោយគោរពទេយ្យវត្ថុដែលត្រូវលះឱ្យ និងគោរពបដិគ្គាហកៈអ្នកទទួល; គោរពទេយ្យវត្ថុនោះ ត្រូវសំអាតទេយ្យវត្ថុដោយផ្ចិតផ្ចង់ មិនធ្វើខ្ជីខ្ជាតាមតែបាន, ឯគោរពបដិគ្គាហកៈនោះត្រូវសំដែងសេចក្តីរាប់រកបដិគ្គាហកៈ ដោយសេចក្តីស្មោះស្ម័គ្រ មិនសំដែងអាការទ្រមឹងទ្រមើយ គឺត្រូវនិមន្ត ឬអញ្ជើញឡើងអាសនៈ ដ៏សមគួរជាដើម

**៣~ កាលេន ទានំ ទេតិ** ឱ្យទានតាមកាលគួរ គឺឱ្យតាមកាល

តាមរដូវ ដែលគេត្រូវធ្វើត្រូវឱ្យ ដូចរដូវចូលវស្សានឹងចេញវស្សារដូវរងាឱ្យគ្រឿងស្លៀកដណ្ដប់ រដូវក្ដៅឱ្យទឹក ឬក៏ពេលដែលមានវត្ថុថ្មីថ្មោងមានផ្លែឈើជាដើម

**៤. អនុគ្គហិតចិត្តោ ទានំ ទេតិ** ឱ្យទានដោយសេចក្ដីអនុគ្រោះ គឺឱ្យដោយចិត្តមេត្តាយ៉ាងទោរទន់ ចំពោះសមណៈ ឬ អ្នកក្រីក្រលំបាក ដែលរងទុក្ខវេទនាដោយសេចក្ដីស្រេកឃ្លានជាដើម ឱ្យបានសុខស្រួលផុតអំពីសេចក្ដីទុក្ខព្រួយ ហើយឥតតាំងចិត្តថា នឹងទារយកគុណបំណាច់អ្វីអំពីអ្នកទទួលទាននោះវិញឡើយ

**៥. អត្តានញ្ច បរញ្ច អនុបហច្ច ទានំ ទេតិ** ឱ្យទានដោយមិនបានតាំងចិត្តបៀតបៀនខ្លួនឯងនិងអ្នកដទៃ គឺឱ្យដោយតាំងចិត្តថា នឹងបំបាត់បង់នូវសេចក្ដីលោភនិងសេចក្ដីកំណាញ់ ហើយនឹងធ្វើឱ្យអស់អាសវក្កិ-លេស ដែលជាមេនាំឱ្យកើតសេចក្ដីទុក្ខព្រួយក្នុងវដ្តសង្សារប៉ុណ្ណោះ មិនបានតាំងចិត្តឱ្យអ្នកផងគេស្ងើចសរសើរថាប្រសើរជាងអ្នកដទៃឡើយ, ដែលថាមិនបៀតបៀនខ្លួន គឺមិនឱ្យអ្នកដទៃសរសើរខ្លួន, មិនបៀតបៀនអ្នកដទៃ គឺមិនបង្អាប់បន្ទាបអ្នកដទៃ ។

**បុ. សប្បុរិសទាន** មានត្រឹមតែ ៥ ប៉ុណ្ណោះទេ ឬ មានផ្សេងពីនេះទៀតប៉ុន្មានយ៉ាង ? បើមានចូររាប់ចំនួន ហើយអធិប្បាយមួយៗ មកផង !

**វិ.** មានផ្សេងពីនេះ ៥ យ៉ាងទៀតគឺ :



**១. សក្កច្ចំ ទេតិ** ឱ្យទានដោយសេចក្ដីគោរពចំពោះវត្ថុដែលត្រូវឱ្យ

**២. ចិត្តីកត្វា ទេតិ** ឱ្យទានដោយតាំងសេចក្ដីគោរពចំពោះវត្ថុនិងបដិគ្គាហកៈ

**៣. សហត្ថា ទេតិ** ឱ្យទានដោយដៃខ្លួនឯង

**៤. អនបវិទ្ធំ ទេតិ** ឱ្យទានដោយមិនបោះឱ្យ

**៥. អាគមនទិដ្ឋិកោ ទេតិ** ឱ្យទានដោយចិត្តជឿថានឹងបានទទួលផលដោយពិត ។

អធិប្បាយថា: ទាយកកាលដែលធ្វើទាន បានតាំងចិត្តគោរពចំពោះតែវត្ថុប៉ុណ្ណោះ មិនធ្វើសេចក្ដីអើពើចំពោះបុគ្គលអ្នកទទួល ទោះអ្នកទទួលទាននោះ មានចរិយាដូចម្ដេច ក៏ឥតរវល់ ខំប្រឹងតែគិតសម្រិតសម្រាំងទេយ្យវត្ថុដែលខ្លួនត្រូវលះឱ្យនោះ ឱ្យស្អាតតែម្យ៉ាង យ៉ាងនេះហៅថា ឱ្យទានដោយសេចក្ដីគោរពចំពោះវត្ថុ ។

បុគ្គលកាលដែលធ្វើទាន បានតាំងចិត្តគោរពចំពោះទេយ្យវត្ថុផងចំពោះបុគ្គលអ្នកទទួលទានផង ទាំងពីរយ៉ាងគឺខំប្រឹងរៀបចំចាត់ចែងទេយ្យវត្ថុនោះឱ្យទាល់តែបានប្រសើរថ្លៃថ្លា មានឱជារសឆ្ងាញ់ពិសាផងទាំងពិនិត្យមើលបុគ្គលអ្នកទទួលទានឱ្យឃើញថា មានចរិយាសណ្ដាប់ធ្នាប់ជាដើម ក៏ល្មមជាទីជ្រះថ្លាគួរកក់ក្ដៅក្នុងចិត្តបានផង ហើយក៏ឱ្យដោយសេចក្ដីគោរពចំពោះបុគ្គលអ្នកទទួល មិនព្រមសុខចិត្តប្រថុយឱ្យទៅទាំង

ខ្ចីខ្ចាឡើយ យ៉ាងនេះហៅថា ឱ្យទានដោយតាំងសេចក្តីគោរពចំពោះទាំងវត្ថុនិងបដិគ្គាហកៈ ហើយទើបឱ្យ ។

ទាយកកាលដែលធ្វើទាន បានលើកយកទេយ្យវត្ថុដោយដៃខ្លួនឯង មិនប្រើអ្នកដទៃឱ្យគេឱ្យទេយ្យវត្ថុរបស់ខ្លួននោះជំនួសខ្លួនឡើយ ដោយតាំងចិត្តថា កាលអាត្មាអញត្រាច់រង្គាត់ក្នុងសង្សារវដ្តមិនមានទីបំផុត ដែលមិនមានដៃជើងនោះនឹងប្រមាណមិនបានឡើយ បើដូច្នោះអាត្មាអញនឹងធ្វើឱ្យបានផុតចាកសង្សារវដ្ត នឹងជាគ្រឿងរលាស់ខ្លួនចេញចាកភពយ៉ាងនេះហៅថា ឱ្យទានដោយដៃខ្លួនឯង ។

ទាយកកាលដែលធ្វើទាន មិនបានបោះឱ្យឬចោលឱ្យ គឺលើកហុចឱ្យដោយសេចក្តីគួរសម សំដែងអាការទន់ភ្លន់ ប្រកបដោយចិត្តមេត្តាយ៉ាងនេះហៅថា ឱ្យទានដោយមិនបានបោះឱ្យ ។

ទាយកកាលដែលធ្វើទាន ដោយចិត្តជឿថា បុគ្គលអ្នកឱ្យទានគង់នឹងបានផលជាអំណោយរបស់ទាននោះមកវិញពុំខានឡើយ យ៉ាងនេះហៅថា ឱ្យទានដោយចិត្តជឿថានឹងបានទទួលផលដោយពិត ។

**ប្មុ.** ទានដែលផ្ទុយគ្នានឹងសប្បុរិសទាន ហៅថាទានអ្វី ? ប្រែថាដូចម្តេច ? មានប៉ុន្មានយ៉ាង ? ចូរអធិប្បាយមាតិកាខ្លះ១ មកផង !

**ទិ.** ហៅថា **អសប្បុរិសទាន,** ប្រែថា ទានរបស់បុគ្គលជាអសប្បុរស, មាន ៥ យ៉ាងគឺ:



**១. អសក្កច្ចំ ទេតិ** ឱ្យដោយសេចក្តីមិនគោរពចំពោះវត្ថុ

**២. អចិត្តី កត្វា ទេតិ** ឱ្យដោយមិនតាំងសេចក្តីគោរពចំពោះវត្ថុនិងបដិគ្គាហកៈ

**៣. អសហត្ថា ទេតិ** ឱ្យទានដោយការមិនឱ្យដោយដៃខ្លួនឯង

**៤. អបវិទ្ធំ ទេតិ** ឱ្យទានដោយបោះឱ្យ

**៥. អនាគមនទិដ្ឋិកោ ទេតិ** ឱ្យទានដោយមិនជឿថានឹងបានទទួលផលវិញ ។

អធិប្បាយតែត្រង់ទី ៤-៥ ថាៈ បុគ្គលដែលធ្វើទានដោយបោះឱ្យ ឬចោលឱ្យនោះ គឺបុគ្គលអ្នកឱ្យទានមានចិត្តជឿថា ឱ្យទានបានបុណ្យដែរ ប៉ុន្តែក្នុងពេលដែលស្មូមមកដល់មិនមានចិត្តមេត្តានឹងចង់ឱ្យ ឬជ្រះថ្លានឹងឱ្យទានដល់ស្មូមនោះសោះ ដោយសារតែទាល់ហើយក៏បោះឱ្យទៅ ទោះឋិតនៅក្នុងទីជិតគ្នាល្មមនឹងហុចឱ្យដោយស្រួលបាន ក៏បែរជាបោះឱ្យវិញ ឥតតាំងចិត្តយកបុណ្យឡើយ ពុំនោះសោតដោយសារតែមានទ្រព្យច្រើនក៏ហុចឬបោះឱ្យដើម្បីឱ្យអ្នកក្រីក្រប្រជែងគ្នា ដណ្តើមរើសយក នឹងបានមើលហើយសើចលេងសប្បាយប៉ុណ្ណោះ ។

បុគ្គលដែលធ្វើទាន ដោយមិនជឿថា នឹងបានទទួលផលនោះ គឺបុគ្គលដែលមិនជឿថា មានបុណ្យ មានបាប មាននរក មានសួគ៌ជាដើម មនុស្សក្តីសត្វក្តី កើតឡើងល្អឯង អាក្រក់ឯង ឥតមានបុណ្យបាបអ្វីតាក់តែងឱ្យឡើយ

ដែលឱ្យទាននេះដោយតាំងចិត្តថា ព្រោះតែស្គាល់គ្នាហើយឱ្យទៅ ឬដោយសារមានមនុស្សមកសូមហើយក៏ឱ្យទៅប៉ុណ្ណោះ ឥតមានចិត្តនឹកកក់ក្ដៅឬនឹកសង្ឃឹមថា នឹងបានបុណ្យអំពីទាននេះឡើយ ។

ត្រង់បទទី ១-២-៣ នេះមិនបានអធិប្បាយទេ ព្រោះមានទំនងសេចក្ដីដូចគ្នានឹងសប្បុរិសទានដែរ គ្រាន់តែផ្លាស់ពាក្យថា គោរពនិងមិនគោរពប៉ុណ្ណោះ ។

**បុ.** ទានដែលលោកមិនសន្មត ឬ មិនរាប់ថាជាទាន ហៅថា ទានអ្វី? មានប៉ុន្មានយ៉ាង ? ព្រោះអ្វី ?

**វិ.** ហៅថា **អសម្មតទាន**, មាន ៥ យ៉ាងគឺ :

**១. ឥត្ថីទានំ** ឱ្យស្ត្រីដល់បុរស ឬ ឱ្យបុរសដល់ស្ត្រី

**២. ឧសភទានំ** បើកលែងគោឧសភ គឺគោបា ឬ គោឈ្មោលដល់មេគោ ឬ ឱ្យមេគោ ដល់គោឧសភ

**៣. មជ្ជទានំ** ឱ្យទឹកស្រវឹងមានសុរាជាដើម

**៤. សមជ្ជទានំ** រាំនិងច្រៀងឱ្យជាទាន ឬឱ្យទានរបាំមានច្រៀងរាំត្បុកក្រមាច់ជាដើម

**៥. ចិត្តកម្មទានំ** ឱ្យទានរូបគំនូរស្ត្រីនិងបុរស ដែលជារូបនាំឱ្យកើតតម្រេកត្រេកត្រអាលទៅរកកាម ។



ទានទាំង ៥ នេះមិនសន្មតថាជាទានឡើយ ព្រោះលោកមិនចាត់ថាជាទានបានបុណ្យទេ ជាទានឥតមានផលអ្វីជាទីពឹងពំនាក់ដល់ខ្លួនសោះឡើយ គួរប្រឹងបំពេញតែទានឯទៀត មានសង្ឃគតាទានជាដើមឱ្យបរិបូណ៌ចុះ ព្រោះជាទានមានផលជាកម្រៃជាទីពឹងដោយពិត ។

**បុ.** ដូចម្ដេចហៅថា **កាលទាន** ? មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

**វិ.** ទានដែលគេឱ្យតាមកាលតាមសម័យ ឬ គេឱ្យមួយដងមួយកាលដែលគួរឱ្យ ហៅថា **កាលទាន**, មាន ៥ យ៉ាងគឺ :

**១. អាគន្តុកទានំ** ឱ្យទានដល់អ្នកដែលទើបនឹងមកដល់ថ្មី

**២. គមិកទានំ** ឱ្យទានដល់អ្នកដែលរៀបដំណើរនឹងចេញទៅកាន់ទីឆ្ងាយ

**៣. គិលានទានំ** ឱ្យទានដល់អ្នកជម្ងឺ

**៤. ទុព្ភិក្ខទានំ** ឱ្យទានក្នុងវេលាដែលកំពុងអត់ឃ្លាន

**៥. នវទានំ** ឱ្យទានផ្លែឈើ ឬវត្ថុអ្វីដែលទើបនឹងមានឡើងជាដំបូង ។

**បុ.** ការឱ្យទាន និងការរក្សាសីលទាំងពីរនេះ ណាក្រលំបាកជាងណា? ចូរអធិប្បាយមកមើល !

**វិ.** ការឱ្យទាន ជាកិច្ចដែលបុគ្គលនឹងធ្វើឱ្យបរិសុទ្ធគ្រប់គ្រាន់បានដោយកម្រជាងការកាន់សីល; ចំណែកសីល បើបុគ្គលត្រូវការរក្សាគ្រាន់

តែរៀនឱ្យចេះដឹងកិច្ចដែលត្រូវតម ត្រូវវៀរប៉ុណ្ណោះជាដើម ហើយសមាទានកាន់យកសីលនោះ អំពីសំណាក់ភិក្ខុ ឬសាមណេរជាដើមមកខំប្រឹងប្រព្រឹត្តសង្រួមឱ្យត្រឹមត្រូវតាមច្បាប់នោះប៉ុណ្ណោះ ក៏អាចញុំាងកុសលឱ្យសម្រេចបរិសុទ្ធបាន ឬថាសីលនេះ បុគ្គលទាំងអ្នកមានអ្នកក្រអាចធ្វើបានដូចគ្នា ព្រោះជាកុសលដែលបុគ្គលត្រូវរក្សាចំពោះវិរតិចេតនាម្នាក់ៗ បាន មិនបាច់ដាច់បង់ធនធាន ។

ឯការធ្វើទាន លុះតែបុគ្គលមានទេយ្យវត្ថុល្មមលះធ្វើកើត ទាំងបដិគ្គាហកៈ អ្នកទទួលទានក៏មានផងទើបធ្វើបាន វេលាដែលធ្វើនោះទៀត មានកិច្ចត្រូវខ្វល់ខ្វាយក៏ច្រើន មិនតែប៉ុណ្ណោះឡើយ ទានក្នុងព្រះពុទ្ធ-សាសនានេះ បុគ្គលត្រូវចាត់ចែងធ្វើឱ្យត្រឹមត្រូវតាមពុទ្ធានុញ្ញាតផងទៀត ទើបនឹងបានផលានិសង្សច្រើនពេញលេញសមតាមបំណង បើនឹងចេះតែធ្វើបំពានទាំងខ្វីខ្វា ដោយការមិនចេះដឹង ព្រោះអាងយសស័ក្តិ ឬ ទ្រព្យសម្បត្តិច្រើនធ្វើតាមទំនើងចិត្តចង់ ដោយញាណវិប្បយុត្តមិនអាស្រ័យច្បាប់ព្រះពុទ្ធសាសនា ដែលមានមកក្នុងគម្ពីរដីកាជាគោលផងទេ ទាននេះមិនបានឈ្មោះថាធ្វើដោយប្រពៃឡើយ ទាំងផលនៃទាននោះសោត ក៏ខ្សោយចុះមកជាលំដាប់ ដូច្នេះឃើញថា ការធ្វើទាន ពិបាកជាងការរក្សាសីល ដូចពណ៌នាមកនេះឯង ។

**ឃ. ទក្ខិណាវិសុទ្ធិ** សេចក្តីបរិសុទ្ធិ (និងសេចក្តីមិនបរិសុទ្ធ) នៃ



ការឱ្យទាន មានប៉ុន្មានយ៉ាង ? អ្វីខ្លះ? ចូរអធិប្បាយសេចក្តីឱ្យល្មមស្តាប់បានមកផង !

**ទី.** មាន ៤ យ៉ាងគឺ :

**១. ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ** ទានបរិសុទ្ធអំពីអ្នកឱ្យ មិនបរិសុទ្ធអំពីអ្នកទទួល

**២. បដិគ្គាហកតោ វិសុជ្ឈតិ នោ ទាយកតោ** ទានបរិសុទ្ធអំពីអ្នកទទួល មិនបរិសុទ្ធអំពីអ្នកឱ្យ

**៣. នេវ ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ** ទានមិនបរិសុទ្ធអំពីអ្នកឱ្យផង អំពីអ្នកទទួលផង

**៤. ទាយកតោ ចេវ វិសុជ្ឈតិ បដិគ្គាហកតោ ច** ទានបរិសុទ្ធអំពីអ្នកឱ្យផង អំពីអ្នកទទួលផង ។

អធិប្បាយថា: ទានដែលបរិសុទ្ធអំពីអ្នកឱ្យ មិនបរិសុទ្ធអំពីអ្នកទទួលនោះ គឺអ្នកឱ្យមានសីលបរិសុទ្ធ មានធម៌ល្អ ឯអ្នកទទួលទ្រុស្តសីលមានធម៌អាក្រក់ ។

ទានដែលបរិសុទ្ធអំពីអ្នកទទួល មិនបរិសុទ្ធអំពីអ្នកឱ្យនោះ គឺអ្នកឱ្យជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ ឯអ្នកទទួលជាអ្នកមានសីលបរិសុទ្ធមានធម៌ល្អ ។

ទានដែលមិនបរិសុទ្ធអំពីអ្នកឱ្យផង មិនបរិសុទ្ធអំពីអ្នកទទួលផង

នោះ គឺអ្នកឱ្យជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ ឯអ្នកទទួលក៏ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ដូចគ្នាទាំងពីរខាង ។

ទានដែលបរិសុទ្ធអំពីអ្នកឱ្យផង បរិសុទ្ធអំពីអ្នកទទួលផងនោះ គឺអ្នកឱ្យក៏ជាអ្នកមានសីលបរិសុទ្ធ មានធម៌ល្អ ឯអ្នកទទួលក៏ជាអ្នកមានសីលបរិសុទ្ធ មានធម៌ល្អ ដូចគ្នាទាំងពីរខាង ។

**បុ.** ការធ្វើទានត្រូវប្រកបដោយអង្គប៉ុន្មានយ៉ាង ទើបមានផលានិសង្សច្រើន ?

**វិ.** ត្រូវប្រកបដោយអង្គ ៦ យ៉ាង ទើបមានផលានិសង្សច្រើន ។

**បុ.** អង្គ ៦ យ៉ាងនោះអ្វីខ្លះ ? ចូររាប់មាតិកា ព្រមទាំងអធិប្បាយសេចក្តីមកខ្លះផង !

**វិ.** អង្គ ៦ យ៉ាងនោះគឺ អង្គខាងអ្នកឱ្យ៣, អង្គខាងអ្នកទទួល ៣ ។

## អង្គខាងអ្នកឱ្យ ៣ គឺ

**១. បុព្វេវ ទានា សុមនោ ហោតិ** អ្នកឱ្យមានចិត្តត្រេកអរក្នុងកាលមុនឱ្យ

**២. ទទំ ចិត្តំ បសាទេតិ** អ្នកឱ្យញ៉ាំងចិត្តឱ្យជ្រះថ្លាក្នុងកាលកំពុងឱ្យ

**៣. ទត្វា អត្តមនោ ហោតិ** អ្នកឱ្យទានមានចិត្តត្រេកអរចំពោះទានដែលបានឱ្យរួចទៅហើយ ។



(អង្គទាំង ៣ យ៉ាងនេះនឹងហៅដោយខ្លីថា **បុព្វចេតនា ១ មុញ្ចនចេតនា ១ អបរាបរចេតនា ១** ដូច្នេះវិញក៏បាន) ។

## អង្គខាងអ្នកទទួល ៣ .គឺ

**១. វីតរាគា វា ហោន្តិ រាគវិនយាយ វា បដិបន្នា** បដិបគ្គាហកៈអ្នកទទួលទាន មានរាគៈទៅប្រាស (ពីខន្ធសន្តាន) ហើយ ឬកំពុងប្រតិបត្តិដើម្បីកំចាត់បង់នូវរាគៈ

**២. វីតទោសា វា ហោន្តិ ទោសវិនយាយ វា បដិបន្នា** បដិបគ្គាហកៈអ្នកទទួលទាន មានទោសៈទៅប្រាស (ពីខន្ធសន្តាន) ហើយ ឬកំពុងប្រតិបត្តិដើម្បីកំចាត់បង់នូវទោសៈ

**៣. វីតមោហា វា ហោន្តិ មោហវិនយាយ វា បដិបន្នា** បដិបគ្គាហកៈអ្នកទទួលទាន មានមោហៈទៅប្រាស (ពីខន្ធសន្តាន) ហើយ ឬកំពុងប្រតិបត្តិដើម្បីកំចាត់បង់នូវមោហៈ ។

រួមអង្គទាំងពីរចំណែក គឺទាំងអ្នកឱ្យ ទាំងអ្នកទទួល ត្រូវជា ៦ ប្រការ ហៅថា ឆឡង្គទានៈ ប្រែថា ទានប្រកបដោយអង្គ ៦ ។ ទានប្រកបដោយអង្គ ៦ ប្រការនេះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សរសើរថានឹងបានផលានិសង្សច្រើន បុគ្គលណានីមួយមិនអាចនឹងគណនារាប់ថាមានចំនួនប៉ុណ្ណេះប៉ុណ្ណោះបានឡើយ ។

**បុ.** បើទាយកអ្នកឱ្យទាន បានប្រកបដោយអង្គតែពីរខាងដើម

គឺពេលមុននឹងឱ្យទាន មានចិត្តជ្រះថ្លាីរីករាយ ហៅថា បុព្វចេតនា ១ ពេលកំពុងលះឱ្យ មានចិត្តជ្រះថ្លារីករាយ ហៅថា មុញ្ចនចេតនា ១ លុះឱ្យកន្លងផុតទៅ ស្រាប់តែកើតអកុសលចិត្ត គឺ មច្ឆរិយៈ សេចក្ដីកំណាញ់នឹកស្ដាយចំពោះវត្ថុទាំងប៉ុន្មាន ដែលបានបរិច្ចាគរួចហើយនោះទៅវិញ តើទាយកនោះឈ្មោះថា បានទទួលផលពេញលេញដែរយ៉ាងណា? ចូរទាញឧទាហរណ៍ជាតួយ៉ាងមកផង !

**ទិ.** ឈ្មោះថា បានទទួលផលពេញលេញដែរ ប៉ុន្តែមិនបានសម្រេចប្រយោជន៍អ្វីក្នុងការដែលទទួលផលនោះឡើយ ព្រោះខ្វះអបរាបរចេតនា ១ ខាងចុងទៀត តួយ៉ាងដូចរឿងអបុត្តកសេដ្ឋីនោះកើតជាគហបតីម្នាក់ បានឃើញព្រះបច្ចេកពុទ្ធព្រះនាមតគរសិខី កំពុងនិមន្តបិណ្ឌបាតតាមផ្លូវ ក៏មានសេចក្ដីជ្រះថ្លាហើយស្រែកប្រាប់ទៅភរិយាឱ្យប្រគេនបិណ្ឌបាតដល់លោក លុះប្រាប់ដូច្នោះហើយ ក៏ចេញទៅកាន់ទីដទៃទៅ ចំណែកខាងភរិយា បានឮពាក្យនោះហើយ ក៏ត្រេកអរចាត់ចែងភោជនដ៏ប្រណីតផ្ចិតផ្ចង់ យកទៅដាក់បាត្រប្រគេនព្រះបច្ចេកពុទ្ធអង្គនោះ រួចហើយក៏លោកនិមន្តចេញទៅ ។ គហបតីនោះត្រឡប់មកវិញបានជួបនឹងព្រះបច្ចេកពុទ្ធនោះសួរថា លោកម្ចាស់បានអ្វីខ្លះដែរឬ ? ហើយចូលទៅចាប់បាត្របើកមើលឃើញភោជនយ៉ាងល្អៗ ក៏បែរទៅជានឹកស្ដាយក្រោយថា ឱហ្ន៎ ! បិណ្ឌបាតនេះល្អណាស់តើ ប្រសិនបើបានទាសកម្មករបរិភោគវិញ វានឹងធ្វើការឱ្យអញ ឯសមណៈនេះ យកទៅបរិភោគឥតប្រយោជន៍សោះ ។ គហបតីនោះ លុះបានមកកើតជាអបុត្តសេដ្ឋី ដោយ



អំណាចវិបាកនេះឯង បណ្ដាលឱ្យមានសេចក្ដីកំណាញ់ស្វិតស្វាយហួងហែងទ្រព្យសម្បត្តិទុកមិនឱ្យអ្នកដទៃ ទាំងមិនឱ្យចូលចិត្តប្រើប្រាស់របស់ល្អៗ នេះជាទោស គឺមកអំពីគ្មានចេតនាមួយខាងចុង ហៅថា អបរាបចេតនាហ្នឹងឯង ។

**ម្ចុ.** បដិគ្គាហកៈអ្នកទទួលទាន ដែលថាមានរាគៈ ទោសៈ និង មោហៈ ទៅប្រាសពីខន្ធសន្ដានហើយនោះ តើសំដៅយកបុគ្គលថ្នាក់ណា? ដែលថាកំពុងប្រតិបត្តិដើម្បីកំចាត់បង់នូវ រាគៈ ទោសៈ មោហៈ នោះ តើសំដៅយកបុគ្គលថ្នាក់ណា ?

**ទិ.** បុគ្គលដែលមាន រាគៈ ទោសៈ មោហៈ ទៅប្រាសពីខន្ធសន្ដានហើយសំដៅយកបុគ្គលថ្នាក់ខ្ពស់គឺអរិយបុគ្គល មានសោតាបន្នបុគ្គលជាដើម ឯបុគ្គលដែលកំពុងប្រតិបត្តិដើម្បីកំចាត់បង់នូវ រាគៈ ទោសៈ និង មោហៈ សំដៅយកបុគ្គលថ្នាក់បន្ទាប់ គឺកុលបុត្រដែលលះបង់ឃរាវាសសម្បត្តិហើយចេញទៅបួសក្នុងព្រះពុទ្ធសាសនា ហើយសិក្សារៀនសូត្រចេះដឹងហើយធ្វើសេចក្ដីប្រតិបត្តិដើម្បីកំចាត់បង់នូវកិលេស គឺ រាគៈ ទោសៈ និង មោហៈ ឱ្យអស់ពីខន្ធសន្ដាន បំណងនឹងឱ្យដល់ឋានៈជាអរិយបុគ្គលដូច្នោះដែរ ។

**ម្ចុ.** ការឱ្យទាន ដែលលោកហៅថាជាទានដ៏ប្រសើរខ្ពង់ខ្ពស់ មានប៉ុន្មានប្រការ ? អ្វីខ្លះ ?

**ទិ.** មាន ៧ ប្រការគឺ

**១. តណ្ហុត្តរិយទានំ** ឱ្យទានដើម្បីឆ្លងចាកតណ្ហា ដែលជា

គ្រឿងនាំ ឬ បណ្តើរសត្វឱ្យអន្ទោលកើតស្លាប់ក្នុងភពតូចភពធំ

**២. ចិត្តីការទានំ** ឱ្យទានដោយសេចក្តីគោរព គឺគោរពគ្រប់ទ្វារទាំងបីព្រមទាំងទេយ្យវត្ថុដែលត្រូវលះឱ្យ មិនឱ្យដោយអាការសោះអង្គើយ

**៣. ហិរោត្តប្បទានំ** ឱ្យទានដោយសេចក្តីខ្មាសបាបក្តៅនឹងបាប

**៤. និរវសេសទានំ** ឱ្យទានដោយមិនគិតសំចៃទុក មិននឹកស្តាយក្រោយ

**៥. ទក្ខិណេយ្យទានំ** ឱ្យទានចំពោះទក្ខិណេយ្យបុគ្គល

**៦. សោមនស្សូបវិចារទានំ** ឱ្យទានដោយសោមនស្សរីករាយនិងការពិចារណាឃើញប្រយោជន៍ជាក់លាក់ មិនស្រេវិនស្រវាន់ដោយវិចិកិច្ឆានីវរណៈ

**៧. អលង្ការបរិវារទានំ** ឱ្យទានជាគ្រឿងអលង្ការនិងជាបរិវារនៃចិត្ត គឺតាំងចិត្តថានឹងយកការឱ្យទានមកជាគ្រឿងប្រដាប់សម្រាប់ជាលំអរបស់ចិត្ត ជាគ្នានឹងចិត្ត ។

**បុ.** វត្ថុដែលរាប់បញ្ចូលថាជាភោជនាហារ ហើយហៅថាបិណ្ឌបាត-ប្បច្ច័យនោះ បានដល់វត្ថុណាខ្លះ ?

**វិ.** វត្ថុដែលរាប់បញ្ចូលថាជាភោជនាហារនោះមានច្រើនយ៉ាង គឺបាយ, នំ, ត្រី, សាច់, ផ្លែឈើ, និងមើមឈើជាដើម ។

**បុ.** វត្ថុដែលរាប់បញ្ចូលថាជាភោជនាហារហើយ ទាយកមិនគួរប្រគេនដល់ភិក្ខុក្នុងវេលាណា ? ចូរអធិប្បាយសេចក្តីឱ្យសព្វគ្រប់មកផង !



**វិ.** ទាយកមិនគួរប្រគេនដល់ភិក្ខុក្នុងវេលាវិកាល គឺតាំងពីវេលារសៀលទៅដល់យប់ ឱ្យលោកទទួលផ្ទាល់ដៃឡើយ បើប្រគេនដោយសំដីជាកប្បិយវោហារបាន គឺបវារណាឱ្យលោកដឹង ហើយប្រគល់វត្ថុនោះឱ្យដល់កប្បិយការកៈ គឺកូនសិស្សរបស់លោក អ្នកទទួលរៀបចំទុកដាក់សម្រេចកិច្ចប្រគេន, ចំណែកលោកត្រូវគ្រាន់តែទទួលដឹងដោយចិត្តប៉ុណ្ណោះ បើប្រគេនដូច្នេះទើបលោកឆាន់ភោជននោះទៅថ្ងៃក្រោយទៀតបានឥតមានទោស ។ ភោជននោះកុំថាឡើយតែវត្ថុទទួលផ្ទាល់ដៃក្នុងកាលខុសសូម្បីតែទទួលភោជនណាមួយ ក្នុងកាលត្រូវហើយទុកដាក់ដោយខ្លួនឯងឱ្យកន្លងរាត្រីមួយឡើងទៅ, ភិក្ខុឆាន់ភោជននោះ ត្រូវអាបត្តិបាចិត្តិយត្រង់សន្និធិការកសិក្ខាបទ ដោយពិត ។ មួយទៀត ភោជនាហារ ដែលភិក្ខុត្រូវលេបចូលទៅក្នុងបំពង់កទាំងប៉ុន្មាន លុះតែគេប្រគេនដោយត្រឹមត្រូវទើបភិក្ខុឆាន់បាន វៀរលែងតែទឹកសុទ្ធ គឺទឹកដែលឥតលាយដោយវត្ថុអ្វីមួយនិងឈើស្ទន់ចេញ មិនបាច់ប្រគេនគ្រាន់តែយកទៅដាក់ក្បែរភិក្ខុប្រើប្រាស់ឆាន់បានឥតមានទោស ។

**បុ.** ការប្រគេនវត្ថុអ្វីដល់ភិក្ខុ ត្រូវឱ្យប្រកបដោយអង្គប៉ុន្មានយ៉ាងទើបហៅថាប្រគេន ? អង្គនោះអ្វីខ្លះ ?

**ចំ.** ត្រូវប្រកបដោយអង្គ ៥ យ៉ាង គឺ

**១. ថាមមជ្ឈិមស្ស បុរិសស្ស ឧច្ចារណមត្តំ ហោតិ** វត្ថុដែលមានទម្ងន់ល្មមបុរសមានកម្លាំងយ៉ាងកណ្ដាល លើកម្នាក់ឯងរួច[១]

**២. ហត្ថបាសោ បញ្ញាយតិ** ហត្ថបាសប្រាកដ គឺអ្នកប្រគេនឋិតនៅក្នុងហត្ថបាស ២ ហត្ថ ១ ចំអាម ។

**៣. អភិហារោ បញ្ញាយតិ** អ្នកប្រគេនត្រូវបន្ទន់ខ្លួនបង្អោនវត្ថុចូលមក គឺបង្អោនចូលមកសំដែងឱ្យឃើញថាជាអ្នកត្រូវការប្រគេនពិត ។

**៤. ទេវោ វា មនុស្សោ វា តិរច្ឆានគតោ វា ទេតិ** ទេវតាក្ដី មនុស្សក្ដី សត្វតិរច្ឆានក្ដី ប្រគេន គឺពិតជាមានគេប្រគេនមែន ។

**៥. តំ បន ភិក្ខុ កាយេន វា កាយប្បដិពទ្ធេន វា បដិគ្គណ្ហាតិ** ភិក្ខុទទួលវត្ថុនោះដោយផ្ទាល់កាយក្ដី ដោយវត្ថុដែលជាប់នឹងកាយក្ដី ។

**ឬ.** ត្រង់អង្គទី ២ ពាក្យថា ហត្ថបាសប្រាកដ គឺអ្នកប្រគេនឋិត

---

១-បើវត្ថុគឺភាជនៈដូចតុ, ថាស ជាដើម ដែលគេដាក់តំកល់ខាទនីយៈ និងភោជនីយៈលើនោះ ជារបស់ធ្ងន់ហួសប្រមាណ បើទាយកមិនអាចលើកប្រគេនម្នាក់ឯងរួចទេ គប្បីចូលទៅជិតបដិគ្គាហកៈឱ្យជាប់ហត្ថបាស ហើយចាប់លើកជ្រុងតុ ឬថាសម្ខាងបង្អើមឱ្យផុតបន្តិចឡើងប្រគេនទៅ ក៏ឈ្មោះថាបានប្រគេនដោយពិត ទាំងបដិគ្គាហកៈក៏គួរទទួលឆាន់បានឥតមានទោសឡើយ ។



នៅក្នុងហត្ថបាស ២ ហត្ថ ១ ចំអាមនោះ តើហត្ថបាស ប្រែថាដូចម្ដេច ? កំណត់ទីពីត្រឹមណាទៅទល់ត្រឹមណា ? ទើបឈ្មោះថាឋិតនៅក្នុងហត្ថបាស ២ ហត្ថ ១ ចំអាម ? ចូរអធិប្បាយបញ្ជាក់ឱ្យសព្វគ្រប់មកផង !

**ចំ. ហត្ថបាស** ប្រែថា "អន្ទាក់ដៃ" ក្នុងទីនេះជាឈ្មោះឱកាសដែលត្រូវលាតដៃប្រគេន លាតដៃទទួល មិនលាតលូក ឬ ឈោងដៃចូលទៅឱ្យកើនលើសប្រមាណ ។ ឯពិធីដែលនឹងលៃហត្ថបាស ២ ហត្ថ ១ ចំអាមនោះដូច្នេះគឺ ចំណែកខាងទាយកអ្នកប្រគេន ត្រូវគិតហត្ថបាសពីត្រឹមទីបំផុតខាងក្នុងអវយវៈចូលទៅ, ចំណែកខាងបដិគ្គាហកៈ គឺភិក្ខុអ្នកទទួល ត្រូវគិតពីត្រឹមទីបំផុតខាងក្រៅអវយវៈចូលមក, ផ្សំគ្នាទៅឱ្យបានប្រវែង ២ ហត្ថ ១ ចំអាម គឺបើទាយកឈរប្រគេនចំពីមុខ (ភិក្ខុក៏ឈរទទួល ដូចយ៉ាងទទួលភត្តដែលគេដាក់បាត្រ) ត្រូវគិតពីត្រឹមមេជើងទាយកចូលទៅ ភិក្ខុត្រូវគិតពីចុងបំផុតកែងជើងខ្លួនចូលមក ឱ្យបានប្រវែង ២ ហត្ថ ១ ចំអាម, យ៉ាងនេះហៅថា ហត្ថបាស (មួយអន្ទាក់ដៃ) គឺល្មមលាតដៃប្រគេន លាតដៃទទួលបានដោយគោរព, បុរសក្ដី ស្ត្រីក្ដី អាចប្រគេន ឬដាក់បាត្របានដូចគ្នា ។ ទាយកនិងបដិគ្គាហកៈអង្គុយដូចគ្នាក្ដី ម្នាក់ឈរម្នាក់អង្គុយ ឬ ដេកក្ដី ប្រគេនចំពីមុខក្ដី ពីក្រោយ ឬ ពីខាងក្ដី ក៏មានទំនងដូចន័យនេះដែរ, អ្នកប្រគេនត្រូវគិតពីខាងក្នុងចូលទៅ អ្នកទទួលត្រូវគិតពីខាងក្រៅចូលមក រួមប្រវែងហត្ថបាសទៅឱ្យបាន ២

ហត្ថ ២ ចំអាម, មិនចាំបាច់វាស់ទេ គ្រាន់តែលៃស្មានមើលឱ្យឃើញល្មមបាន ២ ហត្ថ ១ ចំអាមប៉ុណ្ណោះ ឬឱ្យជិតជាងនេះបន្តិចក៏ឥតទាស់ កុំតែឱ្យជិតពេក បើស្ត្រីក្រែងប្រគេន ឬ ដាក់បាត្រពុំបាន ។

**ប្ញ.** ត្រង់អង្គទី ៥ ថាភិក្ខុទទួលវត្ថុនោះ ដោយផ្ទាល់កាយក្តី ដោយវត្ថុដែលជាប់នឹងកាយក្តី ពាក្យថា ទទួលដោយផ្ទាល់កាយនោះដូចម្តេច ? ទទួលដោយវត្ថុដែលជាប់នឹងកាយនោះដូចម្តេច ? ចូរអធិប្បាយឱ្យឃើញដោយឡែកពីគ្នាមក !

**វិ.** ពាក្យថា ទទួលដោយផ្ទាល់កាយនោះ បើទាយកប្រគេនវត្ថុអ្វីមួយភិក្ខុលូកដៃទៅទទួលចាប់កាន់វត្ថុដែលប្រគេននោះផ្ទាល់នឹងដៃ មិនមានយកភាជនៈអ្វីមួយ មានជើងពានជាដើម ទៅទទួលយក ហៅថាទទួលដោយផ្ទាល់កាយ ។

ពាក្យថា ទទួលដោយវត្ថុដែលជាប់នឹងកាយនោះ បើទាយកប្រគេនវត្ថុអ្វីមួយ ភិក្ខុកាន់សំពត់ ឬ ភាជនៈមានជើងពានជាដើម លូកទៅទទួលទស់យក ឬ ផ្ទេរយកវត្ថុដែលគេប្រគេននោះមិនបានទទួលទស់យកផ្ទាល់នឹងដៃសុទ្ធ ហៅថាទទួលដោយវត្ថុដែលជាប់ដោយកាយ ។

**ប្ញ.** ទេយ្យវត្ថុជាពីជគាម ឬ ភូតគាម គឺវត្ថុដែលមានគ្រាប់, មើមដើម, ឫស, ទង ជាពូជល្មមដុះទៅទៀតបាន ដូចផ្លែម្ទេសទុំ, ត្របែកទុំ, ដើមអំពៅ, សណ្តែកបណ្តុះ, ទងដំឡូង, ទងកញ្ឆែតជាដើម បើទាយកមាន



ប្រាថ្នានឹងធ្វើទានដល់សមណៈក្នុងពុទ្ធសាសនាគប្បីធ្វើដូចម្តេច ឱ្យជារបស់គួរលោកទទួលឆាន់បាន ?

**វិ.** គប្បីអុជ, ដុត, ពុះ, ចោះ, ចុច ឬស្រុស ធ្វើឱ្យសម្រេចជារបស់កប្បិយៈ ត្រូវតាមពុទ្ធានុញ្ញាត ដែលព្រះសម្ពុទ្ធទ្រង់អនុញ្ញាតសមណកប្ប ៥ ប្រការដល់ភិក្ខុទាំងឡាយ នោះទើបលោកទទួលឆាន់បាន មិនខុសនឹងវិនយប្បញ្ញត្តិក្នុងភូតគាមសិក្ខាបទ ។

**ប្ញ.** **សមណកប្ប** ប្រែថា ដូចម្តេច ? ដែលថាមាន ៥ ប្រការនោះអ្វីខ្លះ ?

**វិ.** ប្រែថា វត្ថុជារបស់គួរដល់សមណៈឬវត្ថុដែលគួរដល់សមណៈទទួលបរិភោគប្រើប្រាស់បាន, មាន ៥ ប្រការនោះគឺ

១. **អគ្គិបរិចិតំ** វត្ថុដែលគេអុជ, ដុត, កំដៅភ្លើងឬស្រុស

២. **សត្ថបរិចិតំ** វត្ថុដែលគេពុះចោះចិតដោយសស្ត្រា

៣. **នខបរិចិតំ** វត្ថុដែលគេចុច ឬ កេះដោយក្រចក

៤. **អពីជំ** វត្ថុដែលគ្មានពូជដុះតទៅទៀតបាន ( ផ្លែខ្ចី)

៥. **និព្វដ្ដពីជំ** ផ្លែដែលមានពូជបន្លៀចយកគ្រាប់ចេញបាន ។

**ប្ញ.** អង្គនៃការទទួលប្រគេន ៥ ប្រការនិងសមណកប្ប ៥ ប្រការដែលបានពោលរួចមកហើយ ទាយកអ្នកឱ្យទាន គួរសិក្សាឱ្យចាំស្ទាត់ឬទេ? ព្រោះអ្វី ?

**ទិ.** គួរសិក្សាសង្កេតមើលឱ្យចេះចាំចូលចិត្តស្ទាត់កុំខាន ព្រោះជាកិច្ច ឬជាផ្លូវដែលទាយកទាយិកាតែងធ្វើរឿយៗ ដើម្បីកុំឱ្យទាស់ឆ្គងនឹងវិនយ-ប្បញ្ញត្តិ ។

**ប៉ុ.** បច្ច័យទាំង ៤ យ៉ាងគឺ ចីវរប្បច្ច័យ, បិណ្ឌបាតប្បច្ច័យ, សេនា-សនប្បច្ច័យ, គិលានភេសជ្ជប្បច្ច័យ បើទាយកធ្វើទាន ដល់វេលាប្រគេន ត្រូវតែលើកប្រគេនឱ្យជាប់ហត្ថបាសដូចគ្នា ឬ ផ្សេងគ្នាយ៉ាងណា ? ចូរអធិប្បាយមកមើល !

**ទិ.** ផ្សេងគ្នាយ៉ាងនេះ ចីវរប្បច្ច័យនិងសេនាសនប្បច្ច័យ ទាយកប្រគេនដោយវាចា គឺគ្រាន់តែសូត្របាលីវេរ ឬគេនិយាយប្រគេនជាសម្រាយក៏បាន ឈ្មោះថាប្រគេនពិត ភិក្ខុទទួលប្រើប្រាស់បានឥតមានទោស ព្រោះជាបច្ច័យមិនបានលេបចូលទៅក្នុងបំពង់ក ។ ឯបិណ្ឌបាតប្ប-ច្ច័យនិងគិលានភេសជ្ជប្បច្ច័យ ទោះទាយកបាននាំយកមកតំកល់ទុកក្នុងទីចំពោះមុខភិក្ខុសង្ឃជាប់ហត្ថបាសរួចសូត្រវេរជាបាលី ឬ ជាសម្រាយសព្វគ្រប់ហើយក្តី ត្រូវតែទាយកលើកបច្ច័យនោះ ប្រគេនឱ្យត្រូវតាមអង្គប្រគេន ទាំង ៥ ប្រការនោះទៀត ទើបឈ្មោះថាប្រគេន ភិក្ខុក៏ទទួលឆាន់បានឥតមានទោស ។

**ប៉ុ.** ដំណើរការឱ្យទាន រមែងជាប់ទាក់ទងដោយវត្ថុខ្លះ ដោយចេតនាខ្លះ ដោយបុគ្គលអ្នកឱ្យខ្លះ ដោយបុគ្គលអ្នកទទួលខ្លះ តាមឈ្មោះផ្សេងៗ



ពីគ្នា តែបើពោលតាមភូមិនៃបុគ្គលនិងវត្ថុមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ? ចូរអធិប្បាយមក !

**ទិ.** មាន ៣ យ៉ាងគឺ :

១- បុគ្គលណា បរិភោគវត្ថុថោកទាបដោយខ្លួនឯង លុះត្រូវការឱ្យទានដល់បុគ្គលដទៃ ក៏ចាត់ចែងវត្ថុដ៏ថ្លៃថ្លា បុគ្គលនោះឈ្មោះថា **ទានបតិ** ឬ **ទានស្សាមិ** ប្រែថា អ្នកមានទានជាម្ចាស់ គឺថាលើកទានឱ្យជាម្ចាស់របស់ខ្លួន ។

២- បុគ្គលណា បរិភោគវត្ថុបែបណាដោយខ្លួនឯង លុះត្រូវការឱ្យទានដល់បុគ្គលដទៃ ក៏ឱ្យវត្ថុបែបនោះដែរ បុគ្គលនោះឈ្មោះថា **ទានសហាយ** ប្រែថា អ្នកមានទានជាសម្លាញ់ ឬ ជាគ្នា ។

៣- បុគ្គលណា បរិភោគវត្ថុថ្លៃថ្លាខ្លួនឯង លុះវេលាឱ្យទាន ក៏ត្រឡប់ជាយកវត្ថុថោកទាបទៅឱ្យទានដល់បុគ្គលដទៃវិញ បុគ្គលនោះ ឈ្មោះថា **ទានទាសៈ** ប្រែថា អ្នកមានទានជាខ្ញុំ ។

**ប៉ុ.** ការបរិច្ចាគទានតាមភូមិនៃបុគ្គលនិងវត្ថុ ដូចបានពោលមកនេះ តើបានអានិសង្សផ្សេងគ្នាយ៉ាងណាខ្លះ ?

**ទិ.** បានអានិសង្សផ្សេងគ្នាយ៉ាងនេះគឺ បានអានិសង្ស តាមថ្នាក់យ៉ាងខ្ពង់ខ្ពស់ កណ្តាល ថោកទាប តាមលំដាប់នៃទាននោះៗ ដែរ ។

**ប៉ុ.** បើពោលដោយរួបរួមចំពោះអានិសង្ស នៃអាមិសទាននេះមាន

ប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

**វិ.** មាន ៥ យ៉ាងគឺ

**១- បិយោ ហោតិ មនាបោ** អ្នកឱ្យទាន រមែងជាទីស្រឡាញ់ពេញចិត្តនៃអ្នកផងច្រើនគ្នា ដែលនៅជិតខាង ឬ នៅក្នុងទីឆ្ងាយ

**២- សប្បុរិសា ភជន្តិ** ពួកសប្បុរស រមែងរាប់រកសង្គ្រោះនូវបុគ្គលដែលមានសទ្ធាធ្វើទាន ដោយការស្វែងរកប្រយោជន៍ នឹងប្រាថ្នាចង់ឱ្យបុគ្គលនោះ បានសេចក្ដីសុខ ចំរើនគ្រប់កាល

**៣- កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ** កិត្តិស័ព្ទ គឺកេរ្តិ៍ឈ្មោះដ៏ពីរោះ រមែងខ្ចរខ្ចាយផ្សាយទៅក្នុងទិសទាំងពួង ទាំងមនុស្សនិងទេវតា ក៏រមែងឱ្យសព្ទសាធុការ

**៤- វិសារទោ ឧបសង្កមតិ** អ្នកឱ្យទាន ទោះចូលទៅកាន់ចំណោមបរិស័ទណាមួយ រមែងមានសេចក្ដីក្លៀវក្លាអង់អាចមិនក្រអិមក្រអៀម

**៥- សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ** អ្នឱ្យទាន លុះបែកធ្លាយរាងកាយឃ្លាតចាកលោកនេះ ក៏ទៅកើតឯសុគតិសួគ៌ទេវលោក លុះច្យុតចាកទេវលោក ដោយអំណាចឧស្សាហ៍កុសលជាប់មក ក៏បានមកកើតក្នុងមនុស្សលោកនេះទៀត រមែងកើតក្នុងត្រកូលខ្ពស់ ដែលសម្បូណ៌ដោយភោគសម្ប័ទ ។



**បុ.** អានិសង្សទាំង ៥ យ៉ាងដូចពោលមកនោះ ចែកចេញជាប៉ុន្មានផ្នែក ? ផ្នែកប៉ុន្មានជា សន្ទិដ្ឋិកផល, ផ្នែកប៉ុន្មានជាសម្បរាយិកផល ?

**វិ.** ចែកចេញជា ២ ផ្នែកគឺ ផ្នែកអានិសង្ស ៤ ខាងដើម ជាសន្ទិដ្ឋិកផល គឺផលដែលគួរឃើញជាក់ច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្ននេះ, ផ្នែកអានិសង្សមួយខាងចុង ជាសម្បរាយិកផល គឺផលដែលត្រូវជួបប្រសព្វឃើញច្បាស់ក្នុងបរលោក ។

**បុ.** ការធ្វើទាន ដែលអាចឱ្យមានផលានិសង្សច្រើន ត្រូវប្រកបដោយអង្គប៉ុន្មាន? អ្វីខ្លះ ?

**វិ.** ត្រូវប្រកបដោយអង្គ ៣ គឺ អង្គទី ១- ចេតនា, អង្គទី ២- វត្ថុ, អង្គទី ៣- បដិគ្គាហកៈ ។

**បុ.** អង្គទី ១ គឺ ចេតនា នោះ បានដល់ចេតនាយ៉ាងណាខ្លះ ? ចូរអធិប្បាយមកមើល !

**វិ.** បានដល់ចេតនាយ៉ាងនេះគឺ អ្នកឱ្យទានត្រូវញុំាងចេតនាឱ្យជ្រះថ្លាគ្រប់កាលទាំង ៣ គឺពេលមុននឹងឱ្យទាន ត្រូវញុំាងចិត្តរបស់ខ្លួនឱ្យរីករាយចំពោះពេលវេលាដែលខ្លួនបំរុងឱ្យ ១ ក្នុងពេលកំពុងឱ្យ ត្រូវញុំាងចិត្តរបស់ខ្លួនឱ្យរីករាយចំពោះទេយ្យវត្ថុនិងបដិគ្គាហកៈ ១ លុះឱ្យកន្លងរួចទៅហើយ ក៏ត្រូវញុំាងចិត្តរបស់ខ្លួនឱ្យរីករាយថែមទៀត ១ ។

**បុ.** អង្គទី ២ គឺវត្ថុនោះ បានដល់វត្ថុអ្វីខ្លះ ?

**ទិ.** បានដល់វត្ថុ គឺបច្ច័យ មានចីវរបច្ច័យនិងបិណ្ឌបាតបច្ច័យជាដើម ជាបច្ច័យដ៏បរិសុទ្ធប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ ។

**មុ.** អង្គទី ៣ គឺបដិគ្គាហកៈនោះ សំដៅយកបដិគ្គាហកៈ បែបណាខ្លះ ?

**ទិ.** សំដៅយកបដិគ្គាហកៈ ដែលបានកំចាត់ រាគៈ ទោសៈ និងមោហៈ ចេញអស់ពីខន្ធសន្តានហើយ និងលោកដែលនៅកំពុងសិក្សាធ្វើនូវសេចក្តីប្រតិបត្តិដើម្បីកំចាត់នូវរាគៈ ទោសៈ មោហៈ ឱ្យអស់ពីខន្ធសន្តាន ក៏រាប់ថាជា បដិគ្គាហកៈដែរ ។

**មុ.** ទានដែលទាយកឱ្យដល់បដិគ្គាហកៈៗ អាចធ្វើទានរបស់ទាយកនោះ ឱ្យមានផលតិចនិងច្រើនជាងគ្នាពិតឬ ? ព្រោះហេតុអ្វី ? ចូរទាញឧទាហរណ៍និងគ្រឿងប្រៀបមកផង !

**ទិ.** បដិគ្គាហកៈ ធ្វើទានរបស់ទាយកឱ្យមានផលតិចនិងច្រើនជាងគ្នាពិតមែន ព្រោះបដិគ្គាហកៈខ្លះ មានគុណធម៌និងសីលធម៌តិច ខ្លះមានគុណធម៌និងសីលធម៌ច្រើន, ខ្លះឥតមានគុណធម៌និងសីលធម៌អ្វីសោះជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ហេតុនោះបានជាទាយកឱ្យទានមានផលតិចនិងច្រើនជាងគ្នា ដូចមានសេចក្តីសំដែងទុកក្នុងវេលាមសូត្រថាកាលព្រះសម្មាសម្ពុទ្ធជាម្ចាស់យើង កើតជាវេលាមព្រាហ្មណ៍ បានបរិច្ចាគទាន



មានខាទនីយៈ និងភោជនីយៈ (បង្អែមនិងចំអាប), ជាដើមដល់លោកិយមហាជន[១] អស់ ៧ ឆ្នាំ និង ៧ ខែ ឥតមានសល់ថ្ងៃណាមួយឡើយ លុះដល់ថ្ងៃបង្ហើយបុណ្យ ក៏បានបរិច្ចាគទ្រព្យយ៉ាងច្រើនក្រៃលែងគឺ ភាជនៈមាសពេញទៅដោយមាស ភាជនៈប្រាក់ពេញទៅដោយប្រាក់ ភាជនៈសំរិតពេញទៅដោយសំរិត ក្នុងភាជនៈមួយមុខៗ ចំនួនប្រាំបីហ្មឺនបួនពាន់ មិនតែប៉ុណ្ណោះ បានបរិច្ចាគ ដំរី, សេះ, គោ, រថ, ស្រីកញ្ញានិងសំពត់ សុទ្ធតែប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាងទាំងអស់ ក្នុងរបស់នីមួយៗ មានចំនួនប្រាំបីហ្មឺនបួនពាន់ដូចគ្នា ទាននេះ លោកហៅថា **មហាទាន** ។ ទានដែលគេឱ្យដល់សោតាបន្នបុគ្គលតែម្នាក់ មានផលច្រើនជាងមហាទាននោះទៅទៀត, ទានដែលគេឱ្យដល់ សកទាគាមិមបុគ្គលតែម្នាក់ មានផលច្រើនជាងទានដែលគេឱ្យដល់សោតាបន្នបុគ្គលចំនួនមួយរយនាក់ទៅទៀត, ទានដែលគេឱ្យដល់អនាគាមិបុគ្គលតែម្នាក់ មានផលច្រើនជាងទានដែលគេឱ្យដល់សកទាគាមិបុគ្គលចំនួនមួយរយនាក់ទៅទៀត, ទានដែលគេឱ្យដល់បុគ្គលជាព្រះអរហន្តតែម្នាក់ មានផលច្រើនជាងទានដែលគេឱ្យដល់អនាគាមិបុគ្គលចំនួនមួយរយនាក់ទៅទៀត, ទានដែលគេឱ្យដល់ព្រះបច្ចេកពុទ្ធតែមួយអង្គ មានផលច្រើនជាងទានដែលគេឱ្យដល់បុគ្គលជាព្រះអរហន្តចំនួនមួយរយនាក់ទៅទៀត, ទានដែលគេឱ្យដល់ព្រះសម្មាសម្ពុទ្ធតែមួយ

១-ច្រើនតែជនទ្រុស្តសីល សូម្បីតែសរណគមន៍ ៣ ក៏មិនមានផង ។

ព្រះអង្គ មានផលច្រើនជាងទានដែលគេឱ្យដល់ព្រះបច្ចេកពុទ្ធចំនួនមួយរយនាក់ទៅទៀត, ទានដែលគេឱ្យដល់សង្ឃមានព្រះពុទ្ធជាប្រធាន មានផលច្រើនជាងទានដែលគេឱ្យដល់ព្រះសម្មាសម្ពុទ្ធតែមួយព្រះអង្គទៅទៀត, វិហារទាន គឺឱ្យទីនៅ មានកុដិ សាលា ជាដើមដល់សង្ឃ ដែលនិមន្តមកពីទិសទាំង ៤ មានផលច្រើនជាងទាន ដែលគេឱ្យដល់សង្ឃមានព្រះពុទ្ធជាប្រធាននោះទៅទៀត, ប្រៀបដូចដីស្រែ ដែលមានជីវជាតិនិងដីស្រែដែលមិនមានជីវជាតិ ដីស្រែណាដែលមានជីជាតិល្អ អ្នកស្រែយកពូជស្រូវទៅព្រោះសាបក្នុងស្រែនោះ ស្រែនោះឯងក៏អាចបណ្តាលឱ្យមានផលគឺផ្លែផ្កាចំរើនដល់អ្នកម្ចាស់ស្រែនោះវិញ យ៉ាងណាឯបដិគ្គាហកៈណា ដែលមានគុណធម៌ និងសីលធម៌ដ៏បរិសុទ្ធល្អ ទេយ្យវត្ថុដែលទាយកនាំយកទៅតំកល់ទុកក្នុងបដិគ្គាហកៈនោះៗ ឯងអាចធ្វើទានរបស់ទាយកនោះឱ្យមានផលច្រើន ក៏យ៉ាងនោះដែរ ។

មួយទៀត ដីស្រែណាដែលប្រកបដោយក្រួសរវានឥតមានជីជាតិ អ្នកស្រែយកពូជស្រូវទៅព្រោះសាបក្នុងដីស្រែនោះៗ ឯង មិនអាចធ្វើពូជនោះឱ្យមានផលគឺផ្លែផ្កាចំរើនដល់អ្នកម្ចាស់ស្រែនោះវិញ យ៉ាងណា ឯបដិ-គ្គាហកៈដែលមិនមានគុណធម៌និងសីលធម៌ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ទេយ្យវត្ថុដែលទាយកនាំយកទៅតំកល់ទុកក្នុង បដិគ្គាហកៈនោះៗ ឯង មិនអាចធ្វើទានរបស់ទាយកនោះឱ្យមានផលច្រើនឡើយ ក៏យ៉ាងនោះដែរ ព្រោះហេតុនោះបដិគ្គាហកៈ អាចធ្វើទានរបស់ទាយកឱ្យមានផលតិច



និងច្រើនជាងគ្នា យ៉ាងនេះ ។

**ឬ.** បដិគ្គាហកៈ ដែលធ្វើទានរបស់ទាយកឱ្យថយផលមានប៉ុន្មានពួក ? អ្វីខ្លះ ?

**ទិ.** មាន ៨ ពួកគឺ :

១. **មិច្ឆាទិដ្ឋិកា** អ្នកមានសេចក្តីឃើញខុស

២. **មិច្ឆាសង្កប្បា** អ្នកមានការត្រិះរិះខុស

៣. **មិច្ឆាវាចា** អ្នកមានវាចាខុស

៤. **មិច្ឆាកម្មន្តា** អ្នកមានការងារខុស

៥. **មិច្ឆាអាជីវា** អ្នកមានការចិញ្ចឹមជីវិតខុស

៦. **មិច្ឆាវាយាមា** អ្នកមានព្យាយាមខុស

៧. **មិច្ឆាសតិនោ** អ្នកមានសតិខុស

៨. **មិច្ឆាសមាធិនោ** អ្នកមានការតាំងចិត្តខុស ។

**ឬ.** បដិគ្គាហកៈ ដែលធ្វើទានរបស់ទាយកឱ្យមានផលច្រើន មានប៉ុន្មានពួក ? អ្វីខ្លះ ?

**ទិ.** មាន ៨ ពួកគឺ

១. **សម្មាទិដ្ឋិកា** អ្នកមានសេចក្តីយល់ឃើញត្រូវ

២. **សម្មាសង្កប្បា** អ្នកមានការត្រិះរិះត្រូវ

៣. **សម្មាវាចា** អ្នកមានវាចាត្រូវ

៤. **សម្មាកម្មន្តា** អ្នកមានការងារត្រូវ

៥. **សម្មាអាជីវា** អ្នកមានការចិញ្ចឹមជីវិតត្រូវ

៦. **សម្មាវាយាមា** អ្នកមានព្យាយាមត្រូវ

៧. **សម្មាសតិនោ** អ្នកមានសតិត្រូវ

៨. **សម្មាសមាធិនោ** អ្នកមានការតាំងចិត្តត្រូវ ។

**បុ.** ទានណាដែលគេឱ្យដល់សត្វតិរច្ឆានដើម្បីចិញ្ចឹម បំណងឱ្យបរិបូណ៌ដោយគុណមានលក្ខណសម្ប័ទជាដើមក្តី បំណងយកទឹកដោះ ឬឱ្យចាំផ្ទះ ឬក៏ឱ្យថែរក្សាទ្រព្យជាដើមក្តី ទាននោះ លោកសង្គ្រោះថាជាទានបានបុណ្យឬទេ ? ព្រោះហេតុអ្វី ?

**វិ.** ទានដែលអ្នកឱ្យដល់សត្វតិរច្ឆាន ហើយសម្លឹងយកគុណនិងឧបការៈអំពីសត្វតិរច្ឆាននោះៗ វិញ យ៉ាងនេះលោកមិនសង្គ្រោះថាជាទានបានបុណ្យទេ ព្រោះហេតុនៃការឱ្យនោះមិនត្រូវតាមលក្ខណៈរបស់ទាន ។

**បុ.** ការឱ្យទានដល់សត្វតិរច្ឆាន ដែលលោកសង្គ្រោះថាជាទានបានបុណ្យនោះ តើត្រូវឱ្យដោយលក្ខណៈបែបណា ?

**វិ.** ត្រូវឱ្យដោយលក្ខណៈបែបនេះ អ្នកឱ្យទានដល់សត្វតិរច្ឆានមានឆ្កែឆ្មា ជាដើម ប្រកបដោយមេត្តា គឺតាំងចិត្តអនុគ្រោះដោយពិតៗ មិនសម្លឹងយកគុណបំណាច់ឬឧបការៈអ្វីអំពីសត្វនោះៗ វិញទេ ការឱ្យទាន



ដូច្នេះ ទើបលោកសង្គ្រោះថាជាទានបានបុណ្យ ។

**បុ.** អ្នកឱ្យទានដល់បុគ្គលដទៃ គឺឱ្យដោយសេចក្តីខ្លាចគេក្តី ឱ្យដោយតម្រេកស្រឡាញ់គ្នាក្តី ឱ្យដោយការសូកប៉ាន់ក្តី យ៉ាងនេះជាដើមនឹងចាត់ថាជាទានបានបុណ្យដែរឬទេ ? ព្រោះហេតុអ្វី ?

**វិ.** អ្នកឱ្យទានយ៉ាងនេះ នឹងចាត់ថាជាទានបានបុណ្យផងពុំបាន ព្រោះការឱ្យដូច្នោះ ជាទានប្រកបដោយទោស មិនមែនជាលក្ខណៈនៃកុសលចិត្ត ដែលនាំឱ្យកើតទៅជាបុណ្យឡើយ ។

**បុ.** ទានដែលគេឱ្យរលីបរលាបបន្តិចបន្តួច ត្រឹមតែមួយពំនូត ឬត្រឹមតែកន្លះពំនូតប៉ុណ្ណោះ ទាននោះ លោកសង្គ្រោះថាជាទានបានដែរឬទេ? ព្រោះហេតុអ្វី?

**វិ.** ទាននោះ លោកមិនសង្គ្រោះថាជាទានទេ ព្រោះទាននោះ រលីបរលាបមិនអាចឱ្យសម្រេចផលតាមបំណងរបស់អ្នកទទួលបាន គឺអ្នកទទួលមិនអាចញុំាងអត្តភាពឱ្យប្រព្រឹត្តទៅល្មមឆ្អែតគ្រប់គ្រាន់ ដោយសារទាននោះបានឡើយ ។

**បុ.** បុគ្គលអ្នកឱ្យទាន ដែលតាំងចិត្តបែបណាចាត់ជាបាដិបុគ្គលិកទាន? បែបណាចាត់ជាសង្ឃគតាទាន ? ចូរអធិប្បាយមកមើល !

**វិ.** បុគ្គលអ្នកឱ្យទាន គឺឱ្យដោយតាំងចិត្តចំពោះបុគ្គលថាលោកនេះជាភិក្ខុ លោកនេះជាសាមណេរ លោកនេះល្ងង់ លោកនេះចេះ ដូច្នេះជាដើម

ទាននោះហៅថា បាដិបុគ្គលិកទាន បើឱ្យដោយតាំងចិត្តចំពោះថាសង្ឃៗតែម្យ៉ាង ទានរបស់បុគ្គលនោះឈ្មោះថា សង្ឃគតាទានឬសង្ឃគតាទក្ខិណាទាន ដូចទាយកណានីមួយគិតថា អាត្មាអញនឹងឱ្យសង្ឃគតាទក្ខិណាទាន ហើយក៏ចាត់ចែងទេយ្យធម៌បំរុងទុកជាស្រេច ហើយដើរទៅកាន់វត្តនិមន្តលោកដោយពាក្យថា បពិត្រព្រះករុណាដ៏ចំរើន សូមលោកម្ចាស់ចាត់ព្រះថេរៈមួយអង្គ ចំពោះអំពីសង្ឃឱ្យដល់ខ្ញុំព្រះករុណា, លោកក៏ចាត់សាមណេរអំពីសង្ឃបញ្ជូនទៅឱ្យ ទាយកនោះក្រឡេកឃើញក៏ដល់នូវសេចក្តីរាយមាយចិត្តថា ឯងបានទៅជានិមន្តព្រះថេរៈមួយអង្គចំពោះអំពីសង្ឃ ឥឡូវត្រឡប់ជាបានសាមណេរទៅវិញដូច្នេះក្តី ពុំនោះសោត ទុកជាបានព្រះមហាថេរហើយមានសេចក្តីសោមនស្ស ត្រេកអរកើតឡើងថា អីត ! អញបានព្រះមហាថេរអង្គនេះដូច្នេះក្តី ទានរបស់ទាយកនោះ មិនហៅថាសង្ឃគតាទានទេ ទាននោះត្រឡប់ទៅជា បាដិបុគ្គលិកទានទៅវិញ ។ មួយវិញទៀត លុះតែទាយកណាទៅនិមន្តលោក សូម្បីបានលោកអង្គណានីមួយ ទោះជាសាមណេរក្តី ភិក្ខុក្តី ភិក្ខុក្មេងក្តី ភិក្ខុចាស់ក្តី ភិក្ខុល្ងង់ក្តី ភិក្ខុចេះក្តី អំពីសង្ឃមកហើយមិនមានសេចក្តីសន្ទិះសង្ស័យ សំគាល់ថាលោកនេះលោកនោះ ហើយធ្វើសេចក្តីគោរពចំពោះសង្ឃតែម្យ៉ាង ដោយគិតថា អាត្មាអញនឹងឱ្យទានដល់សង្ឃដូច្នេះ ទានរបស់ទាយកនោះ ទើបហៅថាសង្ឃគតាទាន ។



**ឫ.** ទាយកឱ្យទានដល់សមណៈជាបុថុជ្ជនដែលខ្លួននិមន្តទទួលយកចំពោះអំពីសង្ឃមក និងការឱ្យទានដល់សមណៈជាសោតាបន្ន ដែលជាបាដិបុគ្គលិក ដែលខ្លួននិមន្តចំពោះរូបមក ទាំងពីរនេះណាមានផលច្រើនជាង ? ព្រោះហេតុអ្វី ?

**វិ.** ឱ្យទានដល់សមណៈជាបុថុជ្ជនដែលបាននិមន្តយកចំពោះអំពីសង្ឃមកនោះឯង មានផលច្រើនជាងឱ្យទានដល់សមណៈ ជាសោតាបន្នដែលជាបាដិបុគ្គលិក ដែលខ្លួននិមន្តចំពោះរូបបុគ្គលមកព្រោះសមណៈជាបុថុជ្ជននោះ ទាយកបានធ្វើសេចក្តីគោរពចំពោះសង្ឃ ឯសមណៈ ជាសោតាបន្ននោះ ទាយកធ្វើសេចក្តីគោរពចំពោះរូបបុគ្គល ហេតុនោះទើបមានផលតិចជាងគ្នា ឯបដិគ្គាហកៈជាសោតាបន្នបុគ្គលក្តី សកទាគាមិបុគ្គលក្តីជាលំដាប់ឡើងទៅ គប្បីដឹងតាមន័យនេះដូចគ្នា ។

**ឫ.** ទានដែលឱ្យចំពោះរូបបុគ្គល ហៅថា បាដិបុគ្គលិកទាន ដែលឱ្យមិនចំពោះរូបបុគ្គល ហៅថា សង្ឃគតាទាន ឯសង្ឃគតាទាននេះ សំដៅយកលោកប៉ុន្មានអង្គ ទើបឈ្មោះថាសង្ឃក្នុងការឱ្យទាននេះ ? មានសេចក្តីខុសគ្នាពីសង្ឃសម្រាប់ធ្វើកម្មផ្សេងៗ មានឧបោសថកម្មជាដើមយ៉ាងណា? ចូរអធិប្បាយមកមើល !

**វិ.** សង្ឃសម្រាប់ធ្វើទាននិងសង្ឃសម្រាប់ធ្វើកម្មផ្សេងៗ មានឧបោ-សថកម្មជាដើម មានសេចក្តីខុសគ្នាយ៉ាងនេះ គឺសង្ឃសម្រាប់ធ្វើទានមិន

មានកំណត់ចំនួនថាប៉ុណ្ណេះអង្គឬប៉ុណ្ណោះអង្គទេ ដូចទាយកត្រូវការធ្វើទាន ហើយទៅនិមន្តអំពីគណៈសង្ឃមួយអង្គក្តី ពីរអង្គក្តី ឬច្រើនអង្គក្តី ហើយគណៈសង្ឃក៏បានចាត់ភិក្ខុ ឬ សាមណេរតាមចំនួនដែលគេនិមន្ត, ទាយកនោះក៏បានទទួលហើយធ្វើសេចក្តីគោរពចំពោះសង្ឃតែម្យ៉ាង មិនបានតាំងចិត្តសំគាល់ថាលោកនេះ លោកនោះទេ ហើយឱ្យដោយតាំងចិត្តថាអាត្មាអញឱ្យទានដល់សង្ឃ ទាននេះចាត់ជាសង្ឃទាន ឬ សង្ឃគតាទាន ឈ្មោះថាទាយកបានឱ្យទានដល់សង្ឃពេញទី; ឯសង្ឃសម្រាប់ធ្វើកម្មមានឧបោសថកម្មជាដើម លុះតែគ្រប់ចំនួនអង្គ ទើបហៅថាសង្ឃ អាចធ្វើកម្មនោះៗបានដូចឧបោសថកម្ម មានកំណត់ចំនួនភិក្ខុយ៉ាងតិចត្រឹម ៤ អង្គ, កឋិនកម្មមានកំណត់ចំនួនភិក្ខុយ៉ាងតិចត្រឹម ៥ អង្គ បើតិចជាងនេះមិនហៅថាសង្ឃឡើយ ហេតុនេះ សង្ឃសម្រាប់ធ្វើទាននិងសង្ឃសម្រាប់ធ្វើកម្មផ្សេងៗមានឧបោសថកម្មជាដើម មានសេចក្តីខុសគ្នាយ៉ាងនោះឯង ។

**ម្ុ.** ទាយកឱ្យទានដល់បដិគ្គាហកៈ ថ្នាក់ជាន់ទាបនិងថ្នាក់ជាន់ខ្ពស់ដែលមិនមានគុណវិសេស និងមានគុណវិសេស លើសជាងគ្នានោះ តើអំណោយនៃអានិសង្សមានកិរិតផ្សេងគ្នាយ៉ាងណាខ្លះ ?

**ទិ.** អំណោយនៃអានិសង្សមានកិរិតផ្សេងគ្នាយ៉ាងនេះ គឺឱ្យទានដល់សត្វតិរច្ឆាន បានអានិសង្សមួយរយជាតិ, ឱ្យទានដល់មនុស្សបុថុជ្ជនទ្រុស្តសីល បានអានិសង្សមួយពាន់ជាតិ, ឱ្យទានដល់មនុស្សបុថុជ្ជនមានសីលបាន



អានិសង្សមួយសែនជាតិ, ឱ្យទានដល់បុគ្គល (តាបស) ខាងក្រៅព្រះពុទ្ធសាសនា ដែលមានសេចក្តីនឿយណាយក្នុងកាម បានអានិសង្សមួយសែនកោដិជាតិ, ឱ្យទានដល់បុគ្គលដែលប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផល[១] បានអានិសង្សរាប់ពុំបានប្រមាណពុំអស់ឡើយ ។ ចំណែកខាងសោតាបន្នបុគ្គលក្តី បុគ្គលដែលប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវសកទាគាមិផលក្តី សកទាគាមិបុគ្គលក្តី បុគ្គលដែលប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវអនាគាមិផលក្តី អនាគាមិបុគ្គលក្តី បុគ្គលដែលប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវអរហត្តផលក្តី ព្រះអរហន្តជាសាវ័ករបស់ព្រះតថាគតក្តី ព្រះបច្ចេកសម្ពុទ្ធក្តី ព្រះតថាគតជាព្រះអរហន្តសម្មាសម្ពុទ្ធក្តី មិនបាច់និយាយឡើយ គឺថាមានអានិសង្សច្រើនហើយលើសប្រមាណនឹងរាប់កំណត់ចំនួនថាប៉ុណ្ណេះប៉ុណ្ណោះពុំបានឡើយ ។

**ម្ុ.** ហេតុដែលនាំឱ្យធ្វើទានមានប៉ុន្មានយ៉ាង? អ្វីខ្លះ ?

**ទិ.** មាន ៨ យ៉ាងគឺ:

**១~ ឆន្ទទានំ** ឱ្យទានដោយសេចក្តីស្រឡាញ់ពេញចិត្ត

**២~ ទោសទានំ** ឱ្យទានដោយសេចក្តីក្រោធ

---

១-សូម្បីឧបាសកបានដល់ត្រឹមតែសរណគមន៍ ៣ ក្តី កាន់សីល ៥ ក្តី សីល ១០ ក្តី សាមណេរ ឬភិក្ខុទើបនឹងបួសបានមួយថ្ងៃក្តី ភិក្ខុមានវត្តប្រតិបត្តិដែលបួសយូរហើយក្តី ភិក្ខុទ្រទ្រង់វិបស្សនាក្តី ទាំងអស់នេះ ឈ្មោះថាប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផល ។

៣- **មោហទានំ** ឱ្យទានដោយសេចក្តីវង្វេង

៤- **ភយទានំ** ឱ្យទានដោយសេចក្តីខ្លាច

៥- **ទិន្នបុព្វទានំ** ឱ្យទានដោយគិតថាត្រកូលរបស់ខ្លួនធ្លាប់តែឱ្យទានមក

៦- **សុគតិឧប្បជ្ជនទានំ** ឱ្យទានដោយតាំងចិត្តថានឹងបានទៅកើតក្នុងសុគតិ

៧- **ចិត្តប្បសាទនទានំ** ឱ្យទានដោយគិតថាអាត្មាអញកំពុងឱ្យទាននឹងកើតចិត្តជ្រះថ្លា

៨- **ចិត្តាលង្ការទានំ** ឱ្យទានដើម្បីជាគ្រឿងប្រដាប់ឬជាគ្រឿងបរិក្ខារនៃចិត្ត ។

**ប្រ.** បុគ្គលអ្នកឱ្យទានឈ្មោះថាបានឱ្យអ្វីដល់បុគ្គលដទៃ? មួយទៀតអ្នកឱ្យទានឈ្មោះថាជាអ្នកចងមិត្រទុកយ៉ាងដូចម្តេច ?

**ឆ.** បុគ្គលអ្នកឱ្យទានឈ្មោះថាបានឱ្យអាយុ, ឱ្យពណ៌សម្បុរ, ឱ្យសេចក្តីសុខ, ឱ្យកម្លាំង, ឱ្យសេចក្តីអង់អាចដល់បុគ្គលដទៃ; មួយទៀតអ្នកឱ្យទាននោះឈ្មោះថាជាអ្នកចងមិត្រទុក ឬប្រមូលកម្លាំងទុកដោយប្រពៃ ព្រោះថាមនុស្សក្នុងលោក រមែងមានកិច្ចការរវល់ជាធម្មតា កាលបើកិច្ចការដែលត្រូវធ្វើកើតឡើងហើយបុគ្គលអ្នកឥតមិត្រសម្លាញ់រមែងបានសេចក្តីលំបាកដោយកិច្ចការនោះៗ ផ្ទាល់ខ្លួនឯង កាលបើមានមិត្រសម្លាញ់



គ្នីគ្នាច្រើនត្រឹមណា ឈ្មោះថាជាអ្នកមានកម្លាំងរឹងប៉ឹងច្រើនត្រឹមណោះ ។ មួយទៀត ទាននេះចាត់ទុកជាមិត្រសម្លាញ់ជាកម្លាំងដ៏ប្រសើរ ជាបច្ច័យជួយជូនដំណើរឱ្យបានទទួលផលគឺសេចក្តីសុខ សេចក្តីចំរើនដ៏ធំទូលាយតាំងអំពីលោកនេះរហូតដល់លោកខាងមុខ ប្រៀបដូចរាងកាយទាំងមូលត្រូវមានអវយវៈ គឺ ជើងដៃជាមិត្រសម្លាញ់ ឬជាកម្លាំងសម្រាប់ជួយធុរៈបានដោយស្រួលយ៉ាងណាមិញ, បុគ្គលអ្នកមានសទ្ធាត្រេកអរក្នុងការបរិច្ចាគទាន ក៏រមែងបានទាននោះឯង ជាមិត្រជាកម្លាំងរបស់ខ្លួនយ៉ាងនោះដែរ ។

**ប្រ.** បុគ្គលមានភោគសម្ប័ទល្មមនឹងលះធ្វើទៅជាទានបានខ្លះដែរ ទាំងសទ្ធាក៏មានខ្លះដែរ តែមកអំពីមានធម៌អ្វីជាទំនាស់ ឬ ជាគ្រឿងស្ទាក់ដំណើរចិត្តមិនឱ្យចំណាយទ្រព្យធ្វើទៅជាទានកើត? ចូរអធិប្បាយមកមើល!

**ឆ.** មកអំពីមានធម៌គឺមច្ឆរិយៈសេចក្តីកំណាញ់ កើតឡើងជាទំនាស់ ឬរារាំង ស្ទាក់ដំណើរឃាត់ចិត្តមិនឱ្យលះបង់ទ្រព្យធ្វើទៅជាទានកើត តួយ៉ាងដូចបុគ្គលអ្នកធ្វើស្រែ ឬធ្វើជំនួញជាដើម វេលាកំពុងធ្វើមានគំនិតគិតទុកថា របរស្រែឬជំនួញដែលអាត្មាអញធ្វើនេះ កាលណាផលប្រយោជន៍បានសម្រេចហើយ នឹងបរិច្ចាគទ្រព្យធ្វើជាទានក្នុងកាលនោះមិនខាន លុះដល់វេលា ផលប្រយោជន៍បានសម្រេចហើយ ស្រាប់តែមច្ឆេរចិត្ត គឺចិត្តកំណាញ់កើតឡើងរារាំងគិតទុកជាមុនថា ចុះបើអាត្មាអញចំណាយទ្រព្យនោះៗ ធ្វើជាទានអស់ទៅ ខ្លួនអញក្តី ប្រពន្ធកូនរបស់អញក្តី នឹងបានអ្វី

ចិញ្ចឹមជីវិត នឹងបានអ្វីប្រើប្រាស់ក្នុងគ្រួសារនឹងបានអ្វីសន្សំទុកដាក់ការពារទៅមុខ កាលបើសេចក្ដីកំណាញ់ដ៏មានកម្លាំងកើតឡើងគ្របសង្កត់ចាគចិត្ត មិនឱ្យងើបក្បាលរួចដរាបណា បុគ្គលនោះឯង ឈ្មោះថាមិនអាចលះទ្រព្យធ្វើទៅជាទានបានដរាបនោះ ព្រោះហេតុនោះ មច្ឆរិយៈសេចក្ដីកំណាញ់ជាមន្ទិលរាំងស្កាក់ដំណើរបុគ្គលមិនឱ្យធ្វើទានកើតដូច្នេះឯង ។

**មុ.** បុគ្គលឱ្យទានអ្វី ឈ្មោះថាបានបុណ្យទាំងថ្ងៃទាំងយប់គ្រប់វេលា? ព្រោះហេតុអ្វី ?

**ទិ.** បុគ្គលណា ដាំសួនឈើផ្កាក្ដី ដាំសួនឈើដើមក្ដី សាងស្ពានក្ដី ដងទឹកដាក់ពាងតំកល់ទុកឡើបផ្លូវក្ដី ជីកស្រះឬអណ្ដូងក្ដី ធ្វើទីនៅស្នាក់អាស្រ័យមានសាលាជាដើមក្ដី ឱ្យជាទានដល់ជនដទៃ បុណ្យរមែងចំរើនក្រៃលែងដល់បុគ្គលនោះ ទាំងថ្ងៃទាំងយប់គ្រប់វេលា ព្រោះរបស់ទាំងនោះជាសាធារណៈទូទៅដល់ជនទាំងពួង ដែលគេត្រូវការពឹងពាក់អាស្រ័យ មិនមានពេលកំណត់ថាថ្ងៃឬយប់ឡើយ ។

**មុ.** បុគ្គលឱ្យទានអ្វី ឈ្មោះថាឱ្យកម្លាំង ?

**ទិ.** ឱ្យទានគ្រឿងបរិភោគផ្សេងៗ មានបាយនំចំណីជាដើមឈ្មោះថាឱ្យកម្លាំង ។

**មុ.** បុគ្គលឱ្យទានអ្វី ឈ្មោះថាឱ្យពណ៌សម្បុរកាយ ?

**ទិ.** ឱ្យទានគ្រឿងអលង្ការផ្សេងៗ មានសំពត់សម្រាប់ស្លៀកដណ្ដប់



ជាដើម ឈ្មោះថាឱ្យពណ៌សម្បុរកាយ ។

**មុ.** បុគ្គលឱ្យទានអ្វី ឈ្មោះថាបានឱ្យសេចក្ដីសុខ ?

**ទិ.** ឱ្យទានយានជំនិះមានស្បែកជើងនិងឆ័ត្រជាដើម ឈ្មោះថាឱ្យសេចក្ដីសុខ ។

**មុ.** បុគ្គលឱ្យទានអ្វី ឈ្មោះថាឱ្យចក្ខុ (ភ្នែក) ?

**ទិ.** ឱ្យទានប្រទីបគ្រឿងបំភ្លឺ មានចង្កៀងគោមជាដើម ឈ្មោះថាឱ្យចក្ខុ ។

**មុ.** បុគ្គលឱ្យទានអ្វី ឈ្មោះថាឱ្យវត្ថុគ្រប់យ៉ាង ?

**ទិ.** ឱ្យទានទីនៅអាស្រ័យមានសាលារោងជាដើម ឈ្មោះថាឱ្យវត្ថុគ្រប់យ៉ាង ។

**មុ.** បុគ្គលអ្នកឱ្យទានអ្វី ឈ្មោះថាឱ្យនូវព្រះនិព្វាន ?

**ទិ.** អ្នកឱ្យទានធម៌គឺប្រៀនប្រដៅធម៌, បង្ហាត់បង្ហាញធម៌, សំដែងធម៌ឱ្យគេស្ដាប់ ឈ្មោះថាឱ្យនូវព្រះនិព្វាន ។

**មុ.** មានទានមួយទៀតហៅថា អភយទានៗ នោះ ប្រែថាដូចម្ដេច? បានដល់ការប្រព្រឹត្តិយ៉ាងណាខ្លះ ?

**ទិ.** ប្រែថា ការឱ្យអភ័យដល់អ្នកដទៃ ឬធ្វើអ្នកដទៃមិនឱ្យមានភ័យមិនឱ្យមានសេចក្ដីខ្លាច, បានដល់កិរិយាប្រព្រឹត្តកាន់សីល ៥ គឺវៀរចាកការសម្លាប់សត្វ, វៀរចាកការកាន់យករបស់អ្នកដទៃដែលគេមិនបានឱ្យ, វៀរចាកការប្រព្រឹត្តិខុសក្នុងផ្លូវកាម, វៀរចាកការនិយាយកុហក, វៀរចាក

ការផឹកទឹកស្រវឹងគឺសុរានិងមេរ័យ ហៅថា អភយទាន ។

**ម្ុ.** បើគ្រាន់តែការប្រព្រឹត្តិកាន់សីល ៥ ផ្ទាល់ខ្លួនប៉ុណ្ណោះទេ ម៉េចក៏ហៅថា អភយទានដែរ ? បណ្ដាទានទាំងពីរគឺអាមិសទាន និងធម្មទាន អភយទាននេះ សង្គ្រោះចូលក្នុងទានណា? ចូរអធិប្បាយមកមើល !

**ទិ.** ការប្រព្រឹត្តិកាន់សីល ៥ បានជាហៅថាអភយទាន ព្រោះថាសត្វដែលកើតមកក្នុងលោកសន្និវាសនេះ មិនថាសត្វប្រភេទណាឡើង សុទ្ធតែមានសេចក្ដីភ័យខ្លាចវិនាសជីវិតហើយចង់រស់នៅជាធម្មតា, មានសេចក្ដីភ័យខ្លាចវិនាសទ្រព្យសម្បត្តិ ហើយហួងហែងរក្សាទុកជាធម្មតា, មានសេចក្ដីភ័យខ្លាចគេរំលោភក្នុងផ្លូវកាមលើប្រពន្ធកូនរបស់ខ្លួនជាធម្មតា,មានសេចក្ដីភ័យខ្លាចគេកុហកបោកប្រាសបញ្ឆោត ឱ្យខូចប្រយោជន៍របស់ខ្លួនជាធម្មតា, មានសេចក្ដីភ័យខ្លាចគេប្រមាថមើលងាយដល់ខ្លួននិងគ្រួសាររបស់ខ្លួនជាធម្មតា បុគ្គលអ្នករក្សាសីល៥បានវៀរចាកការផ្ដាច់ផ្ដិលជីវិតសត្វឱ្យស្លាប់ ឈ្មោះថាបានឱ្យជីវិតដល់សត្វទាំងពួង, វៀរចាកការលួចយកទ្រព្យសម្បត្តិរបស់ជនទាំងពួង ឈ្មោះថាបានឱ្យសេចក្ដីសុខដល់គេ, វៀរចាកការរំលោភដោយផ្លូវកាមចំពោះប្រពន្ធកូនរបស់ជនទាំងពួងឈ្មោះថាឱ្យសេចក្ដីសុខដល់គេ, វៀរចាកការនិយាយកុហកបញ្ឆោតបោកប្រាសជនទាំងពួង ឱ្យគេខូចប្រយោជន៍ដោយសារសំដីខ្លួន ឈ្មោះថាបានឱ្យសេចក្ដីសុខដល់គេ, វៀរចាកការផឹកទឹកស្រវឹង គឺសុរានិងមេរ័យដែលជាហេតុឱ្យមានសេចក្ដី



កោងកាច ប្រមាថមើលងាយដល់ជនទាំងពួងឈ្មោះថាបានឱ្យសេចក្ដីសុខដល់គេ យ៉ាងនេះឯង ហៅថា អភយទាន។ នេះលោកសង្គ្រោះរួមចូលក្នុងធម្មទានដែរ ។

**ម្ុ.** ទក្ខិណាទាន ដែលអាចឱ្យសម្រេចផលដល់ប្រេតទាំងឡាយត្រូវប្រកបដោយអង្គប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

**ទិ.** ត្រូវប្រកបដោយអង្គ ៣ យ៉ាង គឺ

**១. អត្តនោ អនុមោទនេន** ដោយសេចក្ដីអនុមោទនារបស់ខ្លួន គឺពួកប្រេត (ពួកអ្នកដែលធ្វើមរណកាលទៅកាន់លោកខាងមុខ) បានមកអនុមោទនារីករាយទទួលយកក្នុងខណៈដែលគេឧទ្ទិសដល់ខ្លួន ។

**២. ទាយកានំ ឧទ្ទេសេន** ដោយសេចក្ដីឧទ្ទិសរបស់ទាយកទាំងឡាយ គឺទាយកអ្នកឱ្យទាន ក្នុងវេលាធ្វើទាន ប្រារព្ធនូវបុគ្គលណាក៏ឧទ្ទិសកុសលជូនទៅបុគ្គលនោះ ។

**៣. ទក្ខិណេយ្យសម្បទាយ** ដោយការដល់ព្រមគឺទក្ខិណេយ្យបុគ្គល គឺលោកជាបដិគ្គាហកៈអ្នកទទួលបាន មាននៅជាប្រធានក្នុងទីចំពោះមុខទាយក ។

**ម្ុ.** អ្នកដែលឱ្យទានហើយឧទ្ទិសកុសលជូនទៅឱ្យបេតជន[១] មានមាតាបិតាជាដើម ដែលធ្វើមរណកាលទៅកាន់លោកខាងមុខហើយនោះ

១-ជនដែលទទួលមរណភាពហើយទៅកាន់បរលោក ។

សុទ្ធតែបានដល់ទាំងអស់ ឬ មិនមានដល់ខ្លះដែរ? ប្រសិនបើមិនបានដល់ទៅជននោះទេ តើកុសលដែលអ្នកឧទ្ទិសជូនទៅនោះនឹងទៅជាអ្វីវិញ ?

**ចំ.** មិនមែនបានដល់ទាំងអស់ទេ មានដល់ខ្លះ, មិនដល់ខ្លះ, បើមិនបានដល់ទេ កុសលនោះនឹងត្រូវបានមកអ្នកម្ចាស់ទានវិញ; សូមទាញយករឿងក្នុងសូត្រមួយ ក្នុងគម្ពីរអង្គុត្តរនិកាយ ទសកនិបាត មកឆ្លើយបញ្ជាក់ក្នុងបញ្ហានេះថា មានព្រាហ្មណ៍ម្នាក់ឈ្មោះជាណុស្សោណិ បានចូលទៅក្រាបថ្វាយបង្គំទូលសួរព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គជាព្រាហ្មណ៍ បានឱ្យនូវទានទាំងធ្វើនូវជំនឿថា "ទាននេះរមែងសម្រេចផលដល់ញាតិ និង សាលោហិត ដែលស្លាប់ហើយទៅកាន់បរលោក ចំណែកខាងពួកញាតិនិង សាលោហិតក៏រមែងបានទទួលនូវទាននេះ" បពិត្រព្រះគោតមដ៏ចំរើន ទាននេះបានសម្រេចដល់ពួកញាតិនិងសាលោហិតដែលស្លាប់ហើយទៅកាន់បរលោកដែរឬ ? ឯពួកញាតិនិងសាលោហិតនោះ បានទទួលនូវទាននោះដែរឬ? ។ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ទាននេះ បានសម្រេចក្នុងទីដែលគួរ មិនបានសម្រេចក្នុងទីដែលមិនគួរ ។ ព្រាហ្មណ៍ទូលសួរថា បពិត្រព្រះគោតមដ៏ចំរើន ទីណាដែលគួរ ? ទីណាដែលមិនគួរ ? ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។ល។ ជាអ្នកមានទិដ្ឋិយល់ខុស បុគ្គលនោះ លុះបែកធ្លាយរាងកាយហើយ ទៅកើតក្នុងនរក កម្មវិបាកណាជាអាហាររបស់សត្វ



នរក សត្វនរកនោះរមែងញុំាងអត្តភាពឱ្យប្រព្រឹត្តទៅដោយកម្មវិបាកនោះ ទានដែលគេឧទ្ទិសឱ្យទៅនោះ រមែងមិនសម្រេចដល់សត្វនរកនោះឡើយ ទីនេះឯង ហៅថាទីមិនគួរ ។ មួយទៀត ម្នាលព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។ល។ ជាអ្នកមានទិដ្ឋិយល់ខុស បុគ្គលនោះលុះបែកធ្លាយរាងកាយហើយទៅកើតជាសត្វតិរច្ឆាន វត្ថុមានស្មៅនិងស្លឹកឈើជាដើម ឯណាជាអាហាររបស់សត្វតិរច្ឆាន សត្វតិរច្ឆាននោះរមែងញុំាងអត្តភាពឱ្យប្រព្រឹត្តទៅដោយវត្ថុមានស្មៅនិងស្លឹកឈើជាដើមនោះ ។ ទានដែលគេឧទ្ទិសឱ្យទៅនោះ រមែងមិនសម្រេចដល់សត្វតិរច្ឆាននោះឡើយ ទីនេះឯង ក៏ហៅថា ទីមិនគួរដែរ ។ មួយវិញទៀត បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមិនសម្លាប់សត្វ ។ល។ ជាអ្នកមានទិដ្ឋិយល់ត្រូវ បុគ្គលនោះលុះបែកធ្លាយរាងកាយហើយ ទៅកើតក្នុងកំណើតជាមនុស្ស វត្ថុមានបាយជាដើមឯណា ជាអាហាររបស់មនុស្ស មនុស្សនោះរមែងញុំាងអត្តភាពឱ្យប្រព្រឹត្តទៅដោយវត្ថុមានបាយជាដើមនោះ ទានដែលគេឧទ្ទិសឱ្យទៅនោះ រមែងមិនសម្រេចដល់មនុស្សនោះឡើយ ទីនេះឯង ក៏ហៅថា ទីមិនគួរដែរ ។ មួយវិញទៀត ម្នាលព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមិនសម្លាប់សត្វ ។ល។ ជាអ្នកមានទិដ្ឋិយល់ត្រូវ បុគ្គលនោះលុះបែកធ្លាយរាងកាយហើយ ទៅកើតជាទេវតា វត្ថុមានសុធាភោជនដ៏ទិព្វជាដើមឯណា ជាអាហាររបស់ទេវតា ទេវតានោះរមែងញុំាងអត្តភាពឱ្យប្រព្រឹត្តទៅដោយ

វត្ថុមានសុធាភោជនដ៏ទិព្វជាដើមនោះ ទានដែលគេឧទ្ទិសឱ្យទៅនោះ រមែងមិនសម្រេចដល់ទេវតានោះឡើយ ទីនេះឯង ក៏ហៅថាទីមិនគួរដែរ ។ មួយវិញទៀត ម្នាលព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។ល។ ជាអ្នកមានទិដ្ឋិយល់ខុស បុគ្គលនោះលុះបែកធ្លាយរាងកាយហើយទៅកើតជាប្រេត វត្ថុមានទឹកមាត់និងទឹកសំបោរជាដើមឯណា ជាអាហាររបស់ប្រេត ប្រេតនោះរមែងញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅដោយវត្ថុមានទឹកមាត់និងទឹកសំបោរជាដើមនោះ តែបើមានញាតិនិងសាលោហិតគេឧទ្ទិសផលនៃទានណាអំពីលោកនេះទៅដើម្បីប្រេតនោះៗ ឯង រមែងញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅដោយផលទាននោះ ទានដែលគេឧទ្ទិសឱ្យទៅនោះ រមែងសម្រេចដល់ប្រេតនោះបាន ទីនេះឯងហៅថាទីគួរ ។ ព្រាហ្មណ៍ទូលសួរថា បពិត្រព្រះគោតមដ៏ចំរើន ប្រសិនបើញាតិនិងសាលោហិតដែលស្លាប់ហើយគ្មានទៅកើតជាប្រេតទេ តើបានអ្នកណាទទួលនូវទាននោះ ? ព្រះមានព្រះភាគត្រាស់ថា ម្នាលព្រាហ្មណ៍ ពួកញាតិនិងសាលោហិតដទៃទៀតរបស់បុគ្គលនោះ ដែលស្លាប់ហើយទៅកើតជាប្រេត ទទួលនូវទាននោះឯង ។ ព្រាហ្មណ៍ទូលសួរទៀតថា បពិព្រះគោតមដ៏ចំរើន ចុះប្រសិនបើ ញាតិនិងសាលោហិតនោះដែលស្លាប់ហើយគ្មានទៅកើតជាប្រេតទេ ទាំងពួងញាតិនិងសាលោហិតដទៃទៀតរបស់បុគ្គលនោះ ដែលស្លាប់ហើយក៏គ្មានទៅកើតជាប្រេតដែរ តើបានអ្នកណាទទួលនូវទាននោះ? ព្រះសម្ពុទ្ធ



ត្រាស់ថា ម្នាលព្រាហ្មណ៍ទីណាដែលសូន្យស្ងាត់អស់កាលជាអង្វែង គ្មានញាតិនិងសាលោហិតណាមួយដែលស្លាប់ហើយទៅកើតជាប្រេតទេ ទីនោះឯង ហៅថាទីមិនគួរ ទីមិនមែនជាឱកាស ម្នាលព្រាហ្មណ៍ ចំណែកខាងទាយកអ្នកឱ្យទានហើយឧទ្ទិសកុសលជូនដល់បុគ្គលណា ទោះបានសម្រេចដល់បុគ្គលនោះក្តី មិនបានសម្រេចដល់បុគ្គលនោះក្តី ឯទាយកក៏មិនមែនជាឥតផលឡើយ គឺថាផលនៃទាននោះ ត្រូវត្រឡប់បានមកទាយកជាម្ចាស់ទានវិញ ។

**ប្ុ.** ទាយកទាយិកា វេលាដែលធ្វើទានម្តងៗ ខ្លះសូត្រវេរតែជាបាលី, ខ្លះសូត្រវេរតែជាពាក្យសម្រាយ, ខ្លះសូត្រវេរទាំងបាលិទាំងពាក្យសម្រាយ បើច្រើនបែបដូច្នេះ តើសេចក្តីសំខាន់នៅត្រង់សូត្រវេរបែបណា ?

**ទិ.** សេចក្តីសំខាន់នោះ នៅត្រង់យល់ឬដឹងសេចក្តី ទោះបីសូត្រវេរជាភាសាបាលីសុទ្ធក្តី ជាភាសាសម្រាយសុទ្ធក្តី ឱ្យតែស្តាប់សេចក្តីបានហើយត្រូវតាមលក្ខណៈនៃការវេរហើយ ក៏ឈ្មោះថា បានការដូចគ្នាទាំងអស់ ។

**ប្ុ.** កិច្ចដែលលើកប្រគេនតែម្តង និងកិច្ចដែលសូត្រវេរ ផ្សេងគ្នា ឬដូចគ្នា ? ចូរអធិប្បាយមកមើល ?

**ទិ.** ផ្សេងគ្នាដោយវោហារនិងរបៀបដែលធ្វើ ដូចគ្នាដោយសេចក្តីរួមមកក៏គឺការប្រគល់ឱ្យ ឬ លើកឱ្យហ្នឹងឯង ប៉ុន្តែពាក្យថា វេរនេះជាបវេណីម្យ៉ាងរបស់ពុទ្ធបរិស័ទដែលធ្លាប់ធ្វើជាលំដាប់មក គឺរៀបគ្រឿង

សក្ការៈដាក់តាំកល់ទុកក្នុងទីចំពោះមុខនៃភិក្ខុសង្ឃ ហើយម្នាក់សូត្រវេរជាបាលី ឬជាសម្រាយ ឱ្យអ្នកឯទៀតថាតាម ឬក៏សូត្រថាព្រមគ្នាទាំងអស់ក៏បាន មានសេចក្ដីផ្សេងគ្នាខ្លះអំពីពាក្យប្រគេនដូច្នេះឯង ។

**ប្ញ.** បើមិនបាច់សូត្រវេរ លើកប្រគេនផ្ទាល់តែម្ដង និងសូត្រវេរហើយទើបលើកប្រគេនជាខាងក្រោយ កិច្ចទាំងពីរនេះ ណាមានផលច្រើនជាង ឬយ៉ាងណា ? ព្រោះអ្វី ?

**វិ.** កិច្ចទាំងពីរនេះមានផលស្មើគ្នាទេ ប៉ុន្តែកិច្ចដែលសូត្រវេរនោះមានសេចក្ដីវិសេសជាង ព្រោះការសូត្រវេរជាកិច្ចសម្រាប់ធ្វើក្នុងពេលដែលមានគ្នាច្រើននាក់ ដើម្បីប្រមូលឬដាស់តឿនលើកទឹកចិត្ត ឱ្យមូលត្របាញ់ជាមួយគ្នា សំដែងឆន្ទៈ គឺសេចក្ដីពេញចិត្តរីករាយចំពោះក្នុងការលះការឧទ្ទិស ឱ្យបានស្មើភាគគ្នាប៉ុណ្ណោះឯង ។

**ប្ញ.** បើនិយាយតាមផ្លូវធម៌វិញ ការដែលសូត្រវេរជាបាលី ឬជាសម្រាយចំពោះមុខភិក្ខុសង្ឃ ឈ្មោះថាទាយកបានឱ្យដោយវាចា ដាច់ស្រឡះដល់ភិក្ខុសង្ឃហើយ គួរលោកទទួលឆាន់បានឥតមានទោស ចុះហេតុអ្វីបានជាត្រូវឱ្យលើកប្រគេនថែមទៀត ? ព្រោះអ្វី ?

**វិ.** បានជាត្រូវឱ្យលើកប្រគេនថែមទៀតនោះ ព្រោះមានវិនយប្ប-ញ្ញត្តិថា ភិក្ខុទទួលបិណ្ឌបាតប្បច្ច័យក្ដី គិលានភេសជ្ជប្បច្ច័យក្ដី លុះតែទទួលប្រកបដោយអង្គប្រគេនទាំង ៥ យ៉ាង ទើបគួរទទួលឆាន់បានមិនមានទោស



ឯចីវរប្បច្ច័យ និងសេនាសនប្បច្ច័យ បើទាយកសូត្រវេរប្រគេនដោយវាចារួចហើយ ទោះបានលើកប្រគេនថែមទៀតក្ដី មិនបានលើកប្រគេនក្ដី ភិក្ខុគួរទទួលប្រើប្រាស់បាន ឥតមានទោសឡើយ ព្រោះជារបស់ប្រើប្រាស់ផ្ទាល់កាយខាងក្រៅ មិនបានលេបចូលទៅក្នុងបំពង់កដូចជាបិណ្ឌបាតប្បច្ច័យ និងគិលានភេសជ្ជប្បច្ច័យនោះឡើយ ។

**ប្ញ.** បើទាយកទាយិកា មានសេចក្ដីជ្រះថ្លាកើតឡើងក្នុងសន្ដានចិត្ត ហើយប្រាថ្នានឹងចាត់ចែងនូវភត្តណានីមួយ តាមសេចក្ដីពេញចិត្តរបស់ខ្លួនប្រគេនឬវេរដល់ភិក្ខុសង្ឃ ភត្តនោះមានឈ្មោះប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

**វិ.** ភត្តនោះមានឈ្មោះ ១៤ យ៉ាងគឺ:

**១_ សង្ឃភត្តំ** ភត្តដែលប្រគេនដល់ព្រះសង្ឃ

**២_ ឧទ្ទេសភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុមួយអង្គក្ដី ២ អង្គក្ដី ៣ អង្គក្ដី ជាដើម តាមពាក្យដែលសង្ឃចាត់ឱ្យ

**៣_ និមន្តនភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុដែលបាន និមន្តមក

**៤_ សលាកភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុច្រើនអង្គ ដែលគេសរសេរឈ្មោះក្នុងស្លាកហើយចាប់

**៥_ បក្ខិកភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុសង្ឃក្នុងថ្ងៃបក្សទាំងពីរ គឺសុក្កបក្ស ចំណែកខាងខ្នើត, កាឡបក្ស ចំណែកខាងរនោច ក្នុងមួយបក្សប្រគេនតែមួយថ្ងៃ គឺថ្ងៃណាមួយមិនមានកំណត់

**៦. ឧបោសថិកភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុសង្ឃ ក្នុងថ្ងៃឧបោសថ

**៧. បាដិបទិកភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុសង្ឃ ក្នុងថ្ងៃ ១ កើត ឬ ១ រោច

**៨. អាគន្តុកភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុសង្ឃ ដែលទើបមកដល់ថ្មី

**៩. គមិកភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុសង្ឃ ដែលមានដំណើរទៅកាន់ទីណាមួយ

**១០. គិលានភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុសង្ឃ ដែលមានជម្ងឺ

**១១. គិលានុបដ្ឋាកភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុសង្ឃ អ្នករក្សាជម្ងឺភិក្ខុសាមណេរផងគ្នា

**១២. និច្ចភត្តំ** ភត្តដែលត្រូវប្រគេនជានិច្ចដល់ភិក្ខុសង្ឃ

**១៣. កុដិភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុសង្ឃ ដែលនៅក្នុងលំនៅមានកុដិជាដើម ( ភត្តនេះហៅបានតាមឈ្មោះទីកន្លែងដែលសង្ឃនៅ)

**១៤. វារកភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុសង្ឃដោយចាត់ជាវេន ។

ភត្តទាំង ១៤ នេះ បើទាយកប្រាថ្នានឹងវេរភត្តណា ត្រូវលើកយកឈ្មោះភត្តនោះមកដាក់បញ្ចូលត្រង់វង់ក្រចកភ្ជាប់ជាមួយនឹង **ឥមំ** ដែល**មាននៅក្នុង**បាលីវេរនោះស្រាប់ដូចខាងក្រោមនោះ ។



## បាលីវេរភត្ត

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** (៣ចប់) ។

**អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ មាតាបិតុអាទិកេ គុណវន្តេ ឧទ្ទិស្ស (ឥមំ....) សបរិក្ខារំ ពុទ្ធប្បមុខស្ស សង្ឃស្ស ទេម តេ គុណវន្តានយោ (ឥមំ .....) អត្តនោ សន្តកំ វិយ មញ្ញមានា អនុមោទន្តុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈន្តុ សព្វទុក្ខា បមុញ្ចន្តុ ឥមិនា និស្សន្ទេន ។ ទុតិយម្បិ ...។ តតិយម្បិ...។**

ប្រែថា: បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើនអើយ វិចង្ហាន់បិណ្ឌបាតនៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ យើងខ្ញុំទាំងឡាយ សូមឧទ្ទិសចំពោះ ដល់លោកអ្នកមានគុណទាំងឡាយ មានមាតានិងបិតាជាដើម[១] ហើយយើងខ្ញុំទាំងឡាយ វេរនូវ ( . . . នេះ) ព្រមទាំងបរិក្ខារប្រគេនដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន សូមលោកអ្នកមានគុណទាំងឡាយ មានមាតានិងបិតាជាដើមនោះ[២] សំគាល់នូវ ( . . . នេះ) ថាដូចជារបស់នៃខ្លួន ហើយសូមអនុមោទនាយកចុះ លុះអនុមោទនារួចហើយ សូមឱ្យរួចរំដោះចាកទុក្ខទាំងពួង ឱ្យបាន

---

១-២ បើឧទ្ទិសចំពោះឈ្មោះណា ត្រូវដកពាក្យថា "លោកអ្នកមានគុណទាំងឡាយមានមាតានិងបិតាជាដើម" ចេញ ហើយដាក់ឈ្មោះនោះបញ្ចូលមក ។

សម្រេចដោយសម្បត្តិទាំងឡាយ ៣ ប្រការ គឺសម្បត្តិមនុស្ស ១ សម្បត្តិទេវតា ១ សម្បត្តិព្រះនិព្វាន ១ ដោយសមគួរតាមសេចក្តីប្រាថ្នា របស់លោកអ្នកមានគុណទាំងឡាយនោះចុះ ដោយអំណាចផលានិសង្សដែលហូរជូនទៅមិនដាច់នេះហោង ។

. . . អស់វារៈ ២ ដងផង ។ . . . អស់វារៈ ៣ ដងផង ។

## បើវេរចតុប្បច្ច័យចំពោះសង្ឃថាដូច្នេះ

**មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ ... តតិយម្បិ ... ។**

ប្រែថា: បពិត្រព្រះគម្តែងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយបាននាំនូវបច្ច័យទាំងឡាយ ៤ នេះ មកតំកល់ទុកក្នុងទីនេះ ហើយវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលយកនូវបច្ច័យទាំងឡាយ ៤ នេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខគ្រប់ប្រការ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ . . . អស់វារៈពីរដងផង ។ . . . អស់វារៈបីដងផង ។

## បើវេរចតុប្បច្ច័យចំពោះភិក្ខុមួយអង្គថាដូច្នេះ

**មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា**



**អាយស្មតោ ទេម សាធុ ភន្តេ អាយស្មា ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ... ។ តតិយម្បិ... ។**

ប្រែថា: បពិត្រព្រះករុណាម្ចាស់ដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយបាននាំនូវបច្ច័យទាំងឡាយ ៤ នេះ មកតំកល់ទុកក្នុងទីនេះ សូមប្រគេនដល់ព្រះករុណាម្ចាស់មានអាយុ បពិត្រព្រះករុណាម្ចាស់ដ៏ចំរើន សូមព្រះករុណាម្ចាស់ទទួលយកនូវបច្ច័យទាំងឡាយ ៤ នេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខគ្រប់ប្រការ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ . . . អស់វារៈពីរដងផង ។ . . . អស់វារៈបីដងផង ។

## វេរកឋិនទានដល់សង្ឃថាដូច្នេះ

**ឥមំ ទុស្សំ កឋិនចីវរំ សង្ឃស្ស ទេម ។ ទុតិយម្បិ... ។ តតិយម្បិ ... ។**

ប្រែថា: (បពិត្រព្រះគម្តែងសង្ឃដ៏ចំរើនអើយ) យើងខ្ញុំទាំងឡាយសូមវេរនូវសំពត់នេះ ជាសំពត់ដើម្បីកឋិនចីវរ ប្រគេនដល់ព្រះសង្ឃ ។ . . . អស់វារៈពីរដងផង ។ . . . អស់វារៈបីដងផង ។ ឬនឹង វេរថា "**ឥមំ វត្ថំ កឋិនចីវរំ សង្ឃស្ស ទេម**" ដូច្នេះវិញក៏បាន ឯសេចក្តីប្រែដូចគ្នា ។

## វេរគ្រឿងបរិក្ខារជាបរិវារនៃកឋិនដូច្នេះ

**យេនម្ហាកំ កឋិនំ គហិតំ កឋិនានិសំសានិ តស្សេវ ទេម ។ ទុតិយម្បិ ... ។ តតិយម្បិ ... ។**

ប្រែថា: (បពិត្រព្រះគម្ដែងសង្ឃដ៏ចំរើនអើយ) រីកឋិននៃយើងខ្ញុំទាំងឡាយ គឺលោកម្ចាស់អង្គណា បានទទួលកាន់យកហើយ យើងខ្ញុំទាំងឡាយ សូមវេរនូវគ្រឿងបរិក្ខារ ជាបរិវារនៃកឋិនទាំងឡាយប្រគេនដល់លោកម្ចាស់អង្គនោះ ។ . . . អស់វារៈពីរដងផង ។ . . . អស់វារៈបីដងផង ។ សំពត់ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់អនុញ្ញាតទុកឱ្យជាបរិក្ខាររបស់សមណៈ មាន ១០ ប្រការ គឺ:

១. **តិចីវរំ** នូវត្រៃចីវរ

២. **វស្សិកសាដិកំ** នូវសំពត់សម្រាប់ងូតទឹកភ្លៀង

៣. **និសីទនំ** នូវសំពត់សម្រាប់ទ្រាប់អង្គុយ

៤. **បច្ចត្ថរណំ** នូវកម្រាល

៥. **កណ្ឌុប្បដិច្ឆាទី** នូវសំពត់សម្រាប់គ្របបូសឬគ្របដំបៅ

៦. **មុខបុញ្ឆនចោឡំ** នូវសំពត់សម្រាប់ជូតមុខគឺកន្សែង

៧. **បរិក្ខារចោឡំ** នូវសំពត់តូចឬធំជាងប្រមាណជាបរិក្ខារ

៨. **បរិស្សាវនំ** នូវសំពត់សម្រាប់ត្រងទឹក



៩. **វស្សាវាសិកំ** នូវសំពត់ចំណាំវស្សា

១០. **អច្ចេកចីវរំ** នូវសំពត់អច្ចេកចីវរ ។

សំពត់ទាំង ១០ ប្រការនេះ បើត្រូវការនឹងវេរប្រគេនសំពត់ណាមួយ ឱ្យយកឈ្មោះសំពត់នោះមកដាក់ត្រង់កន្លែងដែលមានវង់ក្រចកទុកស្រាប់នោះចុះ ។

**មយំ ភន្តេ ឥមំ[១] (...) ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមំ[១] (. . .) បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ . . . ។ តតិយម្បិ ... ។**

ប្រែថា: បពិត្រព្រះគម្ដែងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយ បាននាំ (នូវ . . .) នេះ មកតំកល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះសង្ឃបពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលយក (នូវ . . .) នេះ ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខគ្រប់ប្រការដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ . . . អស់វារៈពីរដងផង ។ . . . អស់វារៈបីដងផង ។

---

១- បើសំពត់នោះមានចំនួនច្រើន ត្រូវដាក់បាលីជាពហុវចនៈ ថា ឥមានិ តិចីវរានិ នូវត្រៃចីវរទាំងឡាយនេះ, ថា ឥមានិ វស្សិកសាដិកាយោ នូវសំពត់សម្រាប់ងូតទឹកភ្លៀងទាំងឡាយនេះ ។ល។

## វេរសង្ឃទានថា

**មយំ ភន្តេ ឥមានិ ខោទនីយ-ភោជនីយានិ សជ្ជេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមានិ ខាទនីយ ភោជនីយានិ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ... ។ តតិយម្បិ ... ។**

ប្រែថា: បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយ បានចាត់ចែងនូវវត្ថុទាំងឡាយ មានខាទនីយៈ ភោជនីយាហារ គឺបង្អែមនិង ចំអាបជាដើមនេះ ហើយបង្អោនមកវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះ គម្ពែងសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលយកនូវវត្ថុទាំងឡាយ មានបង្អែម និងចំអាបជាដើមនេះ,ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តី សុខគ្រប់ប្រការ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ . . . អស់វារៈពីរដងផង ។ . . . អស់វារៈបីដងផង ។

## វេរគណទានថា

**មយំ ភន្តេ ឥមានិ ខាទនីយ-ភោជនីយានិ សជ្ជេត្វា សីលវន្តានំ ទេម សាធុ ភន្តេ សីលវន្តោ ឥមានិ ខាទនីយ ភោជនីយានិ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ... ។ តតិយម្បិ ... ។**



ប្រែថា: បពិត្រព្រះករុណាម្ចាស់ដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយ បានចាត់ចែងនូវវត្ថុទាំងឡាយ មានខាទនីយៈភោជនីយាហារ គឺបង្អែមនិង ចំអាបជាដើមនេះ ហើយបង្អោនមកវេរប្រគេនដល់លោកម្ចាស់អ្នកមាន សីលទាំងឡាយ បពិត្រព្រះករុណាម្ចាស់ទាំងឡាយដ៏ចំរើន សូមលោកម្ចាស់ អ្នកមានសីលទាំងឡាយ ទទួលយកនូវវត្ថុទាំងឡាយ មានបង្អែម និង ចំអាបជាដើមនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តី សុខគ្រប់ប្រការ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ . . . អស់វារៈពីរដងផង ។ . . . អស់វារៈបីដងផង ។

## វេរបាដិបុគ្គលិកទាន

**មយំ ភន្តេ ឥមានិ ខាទនីយ-ភោជនីយានិ សជ្ជេត្វា សីលវតោ ទេម សាធុ ភន្តេ សីលវា ឥមានិ ខាទនីយ-ភោជនីយានិ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ... ។ តតិយម្បិ ... ។**

ប្រែថា: បពិត្រព្រះករុណាម្ចាស់ដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយ បានចាត់ចែងនូវវត្ថុទាំងឡាយ មានខាទនីយៈភោជនីយាហារ គឺបង្អែមនិង ចំអាបជាដើមនេះ ហើយបង្អោនមកវេរប្រគេន ដល់ព្រះករុណាម្ចាស់ បពិត្រព្រះករុណាម្ចាស់ដ៏ចំរើន សូមលោកម្ចាស់អ្នកមានសីល ទទួលយកនូវ វត្ថុទាំងឡាយ មានបង្អែមនិងចំអាបជាដើមនេះ ដើម្បីសេចក្តីចំរើន

ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខគ្រប់ប្រការ ដល់យើងខ្ញុំទាំងឡាយអស់កាលជាអង្វែងទៅហោង ។ . . . អស់វារៈពីរដងផង ។ . . . អស់វារៈបីដងផង ។

## វេរអង្ករដល់សង្ឃថា

**មយំ ភន្តេ ឥមានិ តណ្ឌុលានិ[១] ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមានិ តណ្ឌុលានិ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ...។ តតិយម្បិ ... ។**

ប្រែថា: បពិត្រព្រះគម្ដែងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយបាននាំនូវអង្ករទាំងឡាយនេះ មកតំកល់ទុកក្នុងទីនេះ ហើយសូមវេរប្រគេនដល់សង្ឃ បពិត្រព្រះគម្ដែងសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលយកនូវអង្ករទាំងឡាយនេះ ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខគ្រប់ប្រការ ដល់យើងខ្ញុំទាំងឡាយអស់កាលជាអង្វែងទៅហោង ។. . . អស់វារៈពីរដងផង ។. . . អស់ វារៈបីដងផង ។

## វេរផ្លែឈើផ្សេងៗថា

**មយំ ភន្តេ ឥមានិ នានាផលានិ ឥធានេត្វា សង្ឃស្ស**

១- បើមានអង្ករផង មានវត្ថុផ្សេងពីអង្ករផង ដាក់វេរជាមួយគ្នាត្រូវជា "តណ្ឌុលាទីនិ នូវវត្ថុទាំងឡាយមានអង្ករជាដើម" ។



**ទេម សាធុ ភន្តេ សង្ឃោ ឥមានិ នានាផលានិ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ...។ តតិយម្បិ ... ។**

ប្រែថា: បពិត្រព្រះគម្ដែងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយបាននាំនូវផ្លែឈើផ្សេងៗ ទាំងឡាយនេះ មកតំកល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់សង្ឃ បពិត្រព្រះគម្ដែងសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលយកនូវផ្លែឈើផ្សេងៗ ទាំងឡាយនេះ ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខគ្រប់ប្រការ ដល់យើងខ្ញុំទាំងឡាយអស់កាលជាអង្វែងទៅហោង ។. . . អស់វារៈពីរដងផង ។. . . អស់ វារៈបីដងផង ។

## វេរគ្រឿងសេនាសនៈ

បើវេររោងឧបោសថ ថា

**មយំ ភន្តេ ឥមំ (ឧបោសថាគារំ) ការេត្វា ឧបោសថ-ប្បវារណាទិសង្ឃកម្មករណត្ថាយ ចាតុទ្ទិសស្ស ភិក្ខុសង្ឃស្ស ទេម សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមំ (ឧបោសថាគារំ) បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ...។ តតិយម្បិ ... ។**

ប្រែថា: បពិត្រព្រះគម្ដែងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយបានចាត់ចែងធ្វើ (នូវរោងសម្រាប់ធ្វើនូវឧបោសថ) នេះ ហើយសូមវេរ

ប្រគេនដល់សង្ឃ ដែលមកអំពីទិសទាំង ៤ ដើម្បីប្រយោជន៍ដល់កិរិយាធ្វើនូវសង្ឃកម្ម មានឧបោសថកម្ម និងបវារណាកម្មជាដើម បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើន សូមព្រះភិក្ខុសង្ឃទទួល (នូវរោងសម្រាប់ធ្វើនូវឧបោសថកម្ម) នេះ ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខគ្រប់ប្រការដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ . . . អស់វារៈពីរដងផង ។ . . . អស់ វារៈបីដងផង ។

**បើវេរសាលា ថា**

**ឥមំ សាលំ** នូវសាលានេះ ។

**វេរកប្បិយកុដិ ថា**

**ឥមំ កប្បិយកុដឹ** នូវកប្បិយកុដិនេះ ។

**វេរកុដិតូច ថា**

**ឥមំ កុដឹ** នូវកុដិតូចនេះ ។

**វេរកុដិធំ ថា**

**ឥមំ វិហារំ** នូវកុដិធំនេះ ។

**វេរបង្គន់ ថា**

**ឥមំ វច្ចកុដឹ** នូវបង្គន់នេះ ។

បើប្រាថ្នានឹងវេរសាលាក្ដី កប្បិយកុដិក្ដី កុដិតូចក្ដី កុដិធំក្ដី បង្គន់ក្ដីទាំង ៥ នេះនឹងវេរសេនាសនៈណាមួយ ឱ្យយកឈ្មោះសេនាសនៈនោះមក



ដាក់ត្រង់កន្លែងដែលវង់ក្រចកនោះ ហើយសូត្រវេរចុះ ។

**វេរគរុភណ្ឌថា**

**មយំ ភន្តេ ឥមំ គរុភណ្ឌំ ឥធានេត្វា ភិក្ខុសង្ឃស្ស ទេម សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមំ គរុភណ្ឌំ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ . . . ។ តតិយម្បិ . . . ។**

ប្រែថា: បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយបាននាំនូវគរុភណ្ឌនេះ មកតំកល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើន សូមព្រះភិក្ខុសង្ឃទទួលយកនូវគរុភណ្ឌនេះ ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខគ្រប់ប្រការ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ . . . អស់វារៈពីរដងផង ។ . . . អស់ វារៈបីដងផង ។

**វេរគ្រឿងភេសជ្ជៈ**

**មយំ ភន្តេ ឥមំ (មដុំ) ឥធានេត្វា ភិក្ខុសង្ឃស្ស ទេម សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមំ (មដុំ) បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ . . . ។ តតិយម្បិ . . . ។**

ប្រែថា៖ បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយបាននាំ (នូវទឹកឃ្មុំ) នេះ មកតំកល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះភិក្ខុសង្ឃ បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើន សូមព្រះភិក្ខុសង្ឃទទួលយក (នូវទឹកឃ្មុំ) នេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខគ្រប់ប្រការ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ ...អស់វារៈពីរ ដងផង ។...អស់ វារៈបីដងផង ។

## បើវេរប្រេង ថា

**តេលំ** នូវប្រេង ។

## បើវេរទឹកអំពៅ ថា

**ផាណិតំ** នូវទឹកអំពៅ ។

## បើវេរទឹកត្នោត ថា

**តាលោទកំ** នូវទឹកត្នោត ។

## បើវេរថ្នាំព្យាបាលរោគថា

**គិលានភេសជ្ជំ** នូវថ្នាំសម្រាប់ព្យាបាលនូវមនុស្សឈឺ ។

បើប្រាថ្នានឹងវេរប្រេងក្តី ទឹកអំពៅក្តី ទឹកត្នោតក្តី ថ្នាំព្យាបាលនូវជម្ងឺក្តី ទាំង ៤ នេះរបស់ណាមួយ ឱ្យយករបស់នោះមកដាក់ត្រង់កន្លែងវង់ក្រចកនោះហើយសូត្រវេរចុះ ។



**ម្.** មាតាបិតាទុកជាបដិគ្គាហកៈ គួរទទួលទេយ្យទានរបស់កូនប្រុស-ស្រីផងបានឬទេ ? ចូរអធិប្បាយទាញគោលមកជាគ្រឿងអាងផង!

**ទិ.** គួរទទួលទេយ្យទានរបស់កូនប្រុស-ស្រីបានដោយពិត ព្រោះក្នុងសព្រហ្មកសូត្រគម្ពីរអង្គុត្តរនិកាយ ចតុក្កនិបាត ព្រះសម្ពុទ្ធទ្រង់សំដែងថា មាតាបិតាជាអាហុនេយ្យបុគ្គលរបស់កូនប្រុស-ស្រីៗ គួរចាត់ចែងវត្ថុដ៏សមគួរហើយបង្អោនចូលទៅបូជា ។ បុគ្គលអ្នកមានសទ្ធាបានចាត់ចែងគ្រឿងសក្ការៈដ៏ថ្លៃថ្លាមានបាយនិងទឹកជាដើម ហើយនាំបង្អោនចូលទៅបូជាបព្វជិតទាំងឡាយក្នុងសាសនាដោយគោរពយ៉ាងណា, ឯកូនប្រុសស្រី ក៏ត្រូវតែចាត់ចែងគ្រឿងសក្ការៈដ៏ផ្ចិតផ្ចង់មានបាយនិងទឹកជាដើម នាំចូលទៅជូនឬបូជាមាតាបិតាដោយគោរព វៀរលែងតែរបស់ណាមួយដែលមាតាបិតាទទួលប្រើប្រាស់ពុំបាន ក៏យ៉ាងនោះដែរ ។

**ម្.** មាតាបិតានៅក្នុងផ្ទះជាមួយ ឬនៅផ្ទះជិតខាងកូនប្រុសស្រីចាត់ចែងវត្ថុមានខាទនីយៈ និងភោជនីយៈ ជាដើម មិនបានអើពើចាប់រំលែកវត្ថុនោះខ្លះ យកទៅជូនមាតាបិតាសិនទេ ហើយនាំបង្ហួសទៅប្រគេនព្រះសង្ឃឯវត្ថុតែម្តង តើកូនប្រុសស្រីនោះឈ្មោះថា ប្រព្រឹត្តដោយប្រពៃចំពោះមាតាបិតាបានឬទេ?

**ទិ.** បើដូច្នោះ មិនបានឈ្មោះថាប្រព្រឹត្តដោយប្រពៃទេ ព្រោះមាតាបិតាលោកទុកថាជាបដិគ្គាហកៈវិសេសមួយផ្នែកខាងក្នុងរបស់កូន១ ពុំគួររំលងចោលឡើយ ព្រោះក្នុងមាតាបិតុឧដ្ឋានសូត្រ ថា សូម្បីកូនបួសជាបព្វជិតហើយដើរទៅស្វែងរកបិណ្ឌបាត បានមកហើយនឹកឃើញដល់មាតាបិតា ដែលកំពង់ខ្សត់ខ្សោយក៏គួរកូនជាបព្វជិតនោះចាប់រំលែកយកទៅជូនមាតាបិតាមុនជានិច្ច ហើយទើបបរិភោគខ្លួនឯងជាខាងក្រោយដែរ ។

## ធម្មទាន

**បុ. ធម្មទាន** ប្រែថា ការឱ្យធម៌ជាទានដល់អ្នកដទៃហៅថាធម្មទាន តើបានដល់ការឱ្យដូចម្តេចខ្លះ ?

**ទិ.** បានដល់ការបង្រៀនធម៌ សំដែងធម៌ប្រាប់អ្នកដទៃ ដូចប្រាប់ថាធម៌នេះជាកុសល ធម៌នេះជាអកុសល ធម៌នេះប្រកបដោយទោសធម៌នេះមិនប្រកបដោយទោសជាដើម ឬសំដែងប្រាប់កម្មនិងផលរបស់កម្ម ឱ្យឃើញជាក់ប្រាកដក្នុងលោកនេះនិងលោកខាងមុខ ហាក់ដូចជាគេចង្អុលប្រាប់ដោយជាក់ច្បាស់នឹងសំដែងធម៌ញុំាងជនដទៃឱ្យងាកបែរចេញអំពីអកុសលធម៌ ហើយឱ្យតំកល់នៅក្នុងកុសលធម៌វិញ ។ មួយយ៉ាងទៀតការខំប្រឹងសរសេរចារចម្លងពុទ្ធវចនៈគឺ ព្រះត្រៃបិដកព្រមទាំងអដ្ឋកថា ឬចំណាយទ្រព្យកសាងគម្ពីរដីកា ច្បាប់ព្រះពុទ្ធសាសនាទុកសម្រាប់ឱ្យសិក្សា



កាមកុលបុត្ររៀនសូត្រឱ្យបានចេះដឹង បានប្រព្រឹត្តកាន់តាម ដើម្បីធ្វើមគ្គផលឱ្យកើតឡើង នឹងបានតវង្សព្រះពុទ្ធសាសនាឱ្យចំរើនតាំងនៅអស់កាលជាយូរអង្វែងតទៅ យ៉ាងនេះជាដើម ហៅថា ធម្មទាន (ឬនឹងហៅថា **លោកិយធម្មទាន** ក៏បាន) ។

**បុ.** ការឱ្យទានធម៌បែបណា ដែលលោកចាត់ថាជាធម្មទានដ៏ខ្ពង់ខ្ពស់ ឬជាកំពូលនៃទានទាំងពួង ?

**ទិ.** ការសំដែងប្រាប់នូវសច្ចៈទាំង ៤ ដល់អ្នកដទៃថា ធម៌នេះបុគ្គលគួរកំណត់ដឹង (កងទុក្ខ), ធម៌នេះបុគ្គលគួរលះបង់ (តណ្ហា), ធម៌នេះបុគ្គលគួរធ្វើឱ្យជាក់ច្បាស់ (និព្វាន), ធម៌នេះបុគ្គលគួរចំរើន (អដ្ឋង្គិកមគ្គ) យ៉ាងនេះជាដើម ហៅថា ធម្មទានជាកំពូលនៃទានទាំងពួង ។

**បុ.** ការឱ្យវត្ថុដែលមានរូប អាចចាប់កាន់ទទួលបាន ចាត់ថាជាអាមិសទានមិនមែនឬ ចុះដូចពុទ្ធវចនៈ គឺធម្មវិន័យជាច្បាប់សំដែងប្រាប់ផ្លូវលោកនឹងផ្លូវធម៌ ដែលគេចារឹតដាក់នឹងក្រដាស ឬ ស្លឹករឹត ហៅថាសៀវភៅ ឬ គម្ពីរ ជារបស់មានរូប អាចចាប់កាន់ទទួលបានដូចគ្នាដែរ នឹងចាត់ថាជាទានអ្វីទៅវិញ ? ព្រោះហេតុអ្វី ?

**ទិ.** ចាត់ថាជាធម្មទានពេញទី ព្រោះហេតុថា សៀវភៅ ឬ គម្ពីរនោះគេគ្រាន់តែចារឹតធម្មវិន័យ ជារបស់មានរូប អាចចាប់កាន់ទទួលបានក៏ពិតមែន ប៉ុន្តែគេមិនអាចបរិភោគលេបចូលទៅក្នុងបំពង់កនឹងមិនអាចប្រើ

ប្រាស់ផ្ទាល់កាយ ដូចជាបច្ច័យទាំង ៤ នោះបានឡើយ ហេតុនេះទើបបាន លោកចាត់ថាជាធម្មទាន ។

**ឬ.** អាមិសទាននិងធម្មទានទាំងពីរនេះ ទានណាមានអានិសង្សខ្ពង់ខ្ពស់ប្រសើរជាង ? ចូរអធិប្បាយមកមើល !

**ចំ.** ធម្មទានមានអានិសង្សខ្ពង់ខ្ពស់ប្រសើរជាង ព្រោះការសំដែងធម៌ជាសាធារណៈដល់បុគ្គលដទៃក្ដី ការប្រៀនប្រដៅប្រាប់អំពីគុណទោស ខុសត្រូវ ក្នុងផ្លូវលោកផ្លូវធម៌ចំពោះមនុស្សម្នាក់ៗ ក្ដី ការបង្ហាត់បង្រៀនធម៌អាថ៌ចំពោះពួកគណៈ សាធារណៈក្ដី ឈ្មោះថាប្រគល់នូវចំណេះវិជ្ជាប្រាជ្ញាស្មារតី ដ៏ធំទូលាយដល់បុគ្គលដទៃ ដូចយ៉ាងបុគ្គលដែលបានទទួលអំណោយសេចក្ដីសុខដោយភោគសម្បទដោយឋានន្តរ គឺតំណែងយសស័ក្តិណាមួយ សុទ្ធតែបានមកអំពីការរៀនសូត្រស្ដាប់ទាំងអស់ ឬថាមានការស្ដាប់នេះឯងជាមូលហេតុ ។ ការសិក្សា ការត្រងត្រាប់ស្ដាប់យកឧបាយ នេះរាប់ថាជាមេគំនិត ឬជាដើមពូជនៃប្រយោជន៍ សេចក្ដីល្អគ្រប់យ៉ាង, បុគ្គលដែលបានសម្រេចមគ្គផលនិព្វានជាគុណវិសេសដ៏ខ្ពស់បំផុត ព្រោះអាស្រ័យការស្ដាប់នេះឯងជាបច្ច័យ ។ ចំណែកខាងបុគ្គលអ្នកប្រៀនប្រដៅធម៌ ឈ្មោះថាឱ្យទានព្រះនិព្វានសមដូចពុទ្ធភាសិតថា **អមតន្ទទោ ច សោ ហោតិ យោ ធម្មមនុសាសតិ** បុគ្គលណាប្រៀនប្រដៅធម៌ បុគ្គលនោះ ឈ្មោះថាឱ្យព្រះនិព្វាន ដល់ជនដទៃ ។ **សព្វទានំ ធម្មទានំ ជិនាតិ** ធម្មទាន



រមែងឈ្នះនូវទានទាំងពួង ។ ធម្មទានជាទានមានផលានិសង្សដ៏ខ្ពង់ខ្ពស់ ឈ្នះទានទាំងអស់ ដោយហេតុថាជាប្រធាន ឬថាជាជីវិតនៃអាមិសទាន ។ ធម្មទានជាអាយុនៃពុទ្ធសាសនា អាចធ្វើពុទ្ធសាសនាឱ្យមានពន្លឺរស្មី រុងរឿងឋិតថេរដរាបទៅ ។ ប្រសិនបើបុគ្គលឱ្យចីវរ ដែលមានសាច់ល្អដូចបណ្ដូលចេកដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះខីណាស្រព ដែលអង្គុយប្រជុំគ្នាត្រៀបត្រាឥតមានចន្លោះ ក្នុងផ្ទៃចក្រវាឡរហូតដល់ព្រហ្មលោក នៅក្នុងទីប្រជុំនោះមានធម្មិកអង្គណាមួយ ធ្វើអនុមោទនាដោយគាថា ៤ បាទ ក៏ប្រសើរជាងចីវរទាននោះទៅទៀត ។ ឯចីវរទាននោះមិនបានមួយចំរៀក នៃគាថានោះដែលគេច្រៀកឱ្យជា ១៦ ចំរៀក អស់វារៈ ១៦ ដង, ចំណែកបិណ្ឌបាតទានក្ដី សេនាសនទានក្ដី គិលានភេសជ្ជទានក្ដី ក៏មានន័យដូចនេះដែរ ព្រោះហេតុនោះ ការសំដែងធម៌ក្ដី ការបង្រៀនធម៌ក្ដី ការស្ដាប់ធម៌ក្ដី ជាការប្រសើរយ៉ាងនេះឯង ។ ដោយហោចទៅ ធម្មទាន គ្រាន់តែបុគ្គលធ្វើអនុមោទនាដោយគាថា ៤ បាទប៉ុណ្ណោះ ក៏នៅតែប្រសើរជាងទានដែលបុគ្គលយកចង្ហាន់បិណ្ឌបាតដ៏ឧត្ដម ដាក់ពេញក្នុងបាត្រហើយឱ្យអរិយបុគ្គលមានព្រះពុទ្ធជាដើម ដូច្នោះផង, ជាងគិលានភេសជ្ជទានដែលបុគ្គលយកសប្បិនិងប្រេងជាដើម ដាក់ពេញក្នុងបាត្រហើយឱ្យដល់អរិយ-បុគ្គលមានព្រះពុទ្ធជាដើមដូច្នោះផង, ជាងសេនាសនទានដែលបុគ្គលសាងវិហារដូចយ៉ាងមហាវិហារ ឬ យ៉ាងលោហប្រាសាទរាប់សែនមិនតែមួយ

ហើយឱ្យដល់អរិយបុគ្គលមានព្រះពុទ្ធជាដើមដូច្នោះផង ព្រោះហេតុអ្វី ព្រោះបុគ្គលដែលចេះលៃលកធ្វើបុណ្យមានសភាពដូច្នោះកើត លុះតែបានស្ដាប់ធម៌ពាក្យប្រៀនប្រដៅជាមុនហើយទើបចេះធ្វើ បើមិនបានស្ដាប់ធម៌សោះទេ ក៏មិនអាចធ្វើអ្វីបានឡើយ ។

មែនពិត សត្វទាំងឡាយបើមិនដែលបានស្ដាប់ធម៌ហើយ សូម្បីតែបបរមួយបោយក្ដី បាយមួយវែកក្ដី ក៏មិនអាចធ្វើទៅជាទានបានឡើយ ។ ធម្មទាន ទើបបានឈ្មោះថា មានផលានិសង្សខ្ពង់ខ្ពស់ប្រសើរជាងអាមិសទានដោយហេតុនេះ ។

**ឬ.** អានិសង្សនៃធម្មទាន បើពោលដោយរួបរួមមានប៉ុន្មានប្រការ ? អ្វីខ្លះ ?

**ទិ.** មាន ៥ ប្រការគឺ

**១. អត្ថប្បដិសំវេទី ធម្មប្បដិសំវេទី** លោកអ្នកសំដែង កាលបើសំដែងដោយផ្ចិតផ្ចង់តាមអង្គនៃធម្មកថិកចំពោះព្រះសទ្ធម្មនីងរីងរឹតតែជាអ្នកយល់ច្បាស់ធ្លុះធ្លាយក្នុងអត្ថក្នុងធម៌ក្រៃលែងតទៅទៀត

**២. បាមោជ្ជ** សេចក្ដីរីករាយក្នុងអត្ថក្នុងធម៌ រមែងកើតឡើង គឺធម្មទេសនានោះ ក៏ពីរោះចាប់ចិត្តខ្លួនឯងនិងបុគ្គលអ្នកស្ដាប់តាមលំដាប់នៃធម៌ដែលលើកឡើងសំដែង

**៣. បីតិ** សេចក្ដីត្រេកអរមានកម្លាំងឆ្អែតចិត្តក្នុងអត្ថក្នុងធម៌នោះៗ



ក៏កើតឡើង

**៤. បស្សទ្ធិ** រូបកាយនិងនាមកាយរបស់លោកអ្នកសំដែងនិងអ្នកស្ដាប់ ក៏ស្ងប់រម្ងាប់ចាកអកុសលធម៌ផ្សេងៗ ដរាបដល់ចិត្តសង្វេគតក់ស្លុតក្នុងសង្ខារទាំងឡាយ

**៥. សមាធិ** ចិត្តរបស់លោកដែលកំពុងសំដែងធម៌ក៏តាំងមាំក្នុងការស្ងប់ស្ងាត់ចាកនីវរណៈ ។ អានិសង្សទាំង ៥ យ៉ាងនេះ ជាសន្ទិដ្ឋិកផល គឺផលដែលឃើញច្បាស់ក្នុងបច្ចុប្បន្ននេះក៏មាន ជាសម្បរាយិកផល គឺផលដែលត្រូវមានជាប់នៅក្នុងបរលោកក៏មាន ។

**ចប់ទានវិនិច្ឆ័យ**

*****

# ធម៌សម្រាប់សូត្រផ្សាយមេត្តាចំពោះសព្វសត្វ ក្នុងទិសទាំង១០

**សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលឋិតនៅ) ក្នុងទិសបូព៌ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ

**សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលឋិតនៅ) ក្នុងទិសអាគ្នេយ៍ សូមកុំឱ្យមានពៀរ នឹងគ្នា មានតែសេចក្តីសុខ

**សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលឋិតនៅ) ក្នុងទិសទក្សិណ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ

**សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលឋិតនៅ) ក្នុងទិសនិរតី សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ

**សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលឋិតនៅ) ក្នុងទិសបស្ចិម សូមកុំឱ្យមានពៀរ នឹងគ្នា មានតែសេចក្តីសុខ